ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ២ លេខ ៨-៩

ខែ មិថុនា - កក្កដា ព.ស. ២៤៩៤

ឆ្នាំសិក្សា ១៩៥០ - ៥១

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K - 2
1950 - 1951
(8-9)

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

### បញ្ជីរឿង

| | |
|---|---|
| | ទំព័រ |
| ឧត្តមដ្ឋាន - មជ្ឈិមដ្ឋានទី ២ ភាសា | ៣ |
| មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា | ១១ |
| កុមារដ្ឋាន - បរិវច្ចណដ្ឋាន ភាសា | ២៥ |
| មជ្ឈិមដ្ឋានទី២ - ឧត្តមដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ - ធរណីមាណសាស្ត្រ | ៣៣ |
| អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី១ នព្វន្ត | ៣៤ |
| មជ្ឈិមដ្ឋានទី ១ នឹងអាទិកដ្ឋាន - ធរណីមាណសាស្ត្រ | ២២ |
| បរិវច្ចណដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៤៣ |
| កុមារដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៤៦ |
| មជ្ឈិមដ្ឋានទី ២ - ឧត្តមដ្ឋាន - វិទ្យាសាស្ត្រ - វិធីបង្ការរោគ | ៥៣ |
| អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ. | ៧៦ |
| លោកនីតិ | ៥៧ |
| មេសូត្រតែមាត់ | ៦៣ |

# ឧត្តមដ្ឋាន

## សាលាបឋមសិក្សាសព្វថ្ងៃ

ការសិក្សាជាន់មុន ផ្លាស់ប្ដូរបែបភាពរបៀបចាត់អស់ទៅហើយ គេលែងតាំងនឹកឃើញថាជាយ៉ាងដូចម្ដេចផង ៗ ក្នុងរបៀបសិក្សាជាន់ដើម សិស្សទៅរៀនមិនចិតថេរទេ ៗ នឹងបង្រៀននោះគ្រូអង្គុយប្ត ទ្រាលលើកំរាលក្ដារ បង្រៀនសិស្សបង្ខំណាស់ដោយឲ្យទន្ទេញរត់មាត់ អក្សរពីរបីក្នុងពេលមួយ ៗ ៗ ឥឡូវនេះហូតដល់ភូមិដាច់ដោច គេឃើញសាលារៀនដ៏មានបន្ទប់ទូលាយភ្លឺស្រឡះមានខ្យល់ចេញចូលពេញលេញ ហើយមានឧកាសយ៉ាងក្សេមក្សាន្តទៅលើវាលស្រែដែលមានទ្រង់ទ្រាយរលាំ ៗ គ្នា ឬទៅលើភូមិដែលមានផ្ទះសុទ្ធតែស្លឹកស្រអាប់ប្រឡង់ទីង ពណ៌ដី ៗ សឹងប្រកបដោយរបៀបរៀបចំត្រឹមត្រូវល្អ សាលាបឋមសិក្សាមានឧបករណ៍សំរាប់ការរៀនគឺសៀវភៅស្វាធ្យាយផ្ទាំងគំនូរផែនទី ផ្ទាំងគំនូររូបព្យួរនៅជញ្ជាំង មានវត្ថុតឹកតាំងរៀបរៀងដោយឡែកគឺសិលាជាតិ លោហជាតិ គ្រាប់រុក្ខជាតិ សាច់ឈើ ស្បែក កំណាត់សំពត់ តឹកតាំងល្អ ៗ មានផ្សេងទៀត ប្រដាប់ធ្វើស្រែចំការដ៏មានទ្រង់ទ្រាយមែន ៗ តូច ៗ ដែលកូនសិស្សធ្វើដោយខ្លួនឯង ៗ

របៀបរៀនប្រជុំតាំងអស់វិជ្ជាសម្រាប់បឋមសិក្សា គឺភាសា ធម្មក្រិត្យ ខ្សែក្សត្រ ឬពង្សាវតារ ភូមិសាស្ត្រ នព្វន្ត វិជ្ជាសាស្ត្រ ដ៏ជាចំណេះប្រក្រតីៗ មិនតែប៉ុណ្ណោះ មានរៀនគូរគំនូរ រៀនការហត្ថកម្មនិងហាត់ពលវិធីទៀតផង ។

ទោះក្នុងខ្ទង់គាពន៍ថែកពេលនៃការរៀនចុះញឹកស្អេកក៏ដោយ ដំ-ណើររៀនសូត្រទៅជាការឲ្យកើតតម្រេក ព្រោះគ្រូបេះញ៉ាំងសិស្សឲ្យត្រេកអរឲ្យក្លាហាន ហើយបង្រៀនតែល្មមសមតាមកម្លាំងក្មេងៗ ជួនគ្រូនាំសិស្សទៅបង្រៀនក្នុងពេលដើរលេងក៏មាន គឺឲ្យមើលគេភ្ជួររាស់ស្រែ គេប្រមូលស្រូវ គេលក់ដូរនៅផ្សារ មើលស្ថានិយ មើលប្រៃសនីយស្ថាន ដែលនៅជិតៗ ។

ពន្យល់ពាក្យ .–

បឋម ឬ ប្រថម = ទី ១ សាលារៀនជាន់ដំបូង ។

ឧបករណ៍ = គ្រឿងប្រដាប់ ។

សិលាជាតិ = ជាតិថ្ម ។

លោហជាតិ = ជាតិដែក, ស្ពាន់, សំណ មាស, ។

ខ្សែក្សត្រ = រឿងដែលកើតឡើងក្នុងរាជ្យស្ដេចនៃប្រទេស

ពង្សាវតារ = រឿងរ៉ាវនៃវង្សត្រកូល ។

ស្ថានីយ = ដំណាក់ឈប់នៃរថភ្លើង (អយស្ម័យយាន)

ប្រៃសនីយ = កន្លែង ឬ មន្ទីរដែលគេដឹកនាំដំណឹងទៅកាន់ ឬ មកពីដំបន់ផ្សេងៗ ។

---

## កប៉ាល់នរម៉ង់ឌី

នរម៉ង់ឌីជាកប៉ាល់សមុទ្រមួយធំបំផុតជាងកប៉ាល់សមុទ្រទាំងឡាយក្នុងលោក បានបើកចេញពីក្រុងហាវ៍ (ហ្វ្រង់) ទៅក្រុងនេវយ៉ក (អាមេរិក) ជាដំបូងនៅឆ្នាំ ១៩៣៥ ។

លុះចូលទៅតាមទន្លេហ៊ុតសុងក៏មានកញ្ចែគំនាប់ហើយនឹងមនុស្សចាំមើលជាច្រើនរយពាន់ ។ យក្សកប៉ាល់នេះវែងដូចជាផ្លូវប្រវែង ៣១៣ ម៉ែត្របណ្ដោយ ទម្ងន់ ៧ កោដិគីឡូក្រាម ល្បឿនលឿន ៥៥ គីឡូម៉ែត្រក្នុងមួយម៉ោង ជាមហានាវាមានល្បឿនសមនឹងទំហំ ។

ជាសមុទ្រយានដ៏មានខមាឱសមតាមរបៀបយានចរដោយស្ទាបបក្រ ដែលគេបានប្រាព្ធគិតសរសេរឡើងយូរលង់ណាស់ ដើម្បីឲ្យមានល្បឿនលឿនហើយមិនឃ្លោង ។ កន្លែងអ្នកដំណើរនៅពីលើតម្ពួយន្តអគ្គីសនីដ៏មានកម្លាំង ១ ម៉ឺន ៨ ពាន់សេះ ដែលឥតបង្អៀតបង្អួលស្រួលក្រៃ

ពេក សន្ទឹកដំឡូងត្រចៀកទឹកចំរុះកើតមានឡើយ ៗ កន្លែងអ្នកជិះ សឹងតាក់តែងឥតខាស់ខ្ចោះឲ្យមានភ័យភិតឡើយ ៗ តួមាឌសឹងខណ្ឌ ៗ ការពារទឹកមិនឲ្យចូលពេញមាឌតែម្តង ហើយមានស្នប់សប់យកទឹកចេញពីខណ្ឌមួយ ៗ យ៉ាងរហ័សវិសេស ៗ ទីងការពារភ្លើង គេយកតែវត្ថុមិនឆេះធ្វើជាគ្រឿងតែង គឺអាលមីញ៉ូម កញ្ចក់ ថ្មកែវ ៗ កំរាលក្តារបន្ទប់ដេក ទីងកន្លែងនៅផ្សេងៗ សឹងសុបដែកបង្ការភ្លើងឆេះ ៗ ការជាបណ្តាប់មកទៀតគេដាក់មេសញ្ញាឆាប់វិសេសដាក់ប្រដាប់លត់ភ្លើងដូចជាពេនពួកលត់ភ្លើងពិត ៗ ៗ

ក្នុងកំឡុងកប៉ាល់បើកទៅ អ្នកជិះមានតែសប្បាយរីករាយព្រោះការក្រសាយការកំសាន្តសប្បាយមានបង្ការស្រេចឥតខ្ចោះមិនខ្វះអ្វីឡើយៗ នៅលើកប៉ាល់ មានក្រុមភ្លេង មានប្រៀង មានស្រះងូតទឹក មានរបៀបចំរើនដែលពីដើមគ្មាន មានស្ពានក្ឈប់ពីកន្លែងសឹងជារានហាលមានថ្នាក់ ៗ របៀបរៀបចំតាំងអស់សឹងសមឥតខាស់ខ្ចោក ៗ បើសំឡឹងពីបន្ទប់ល្បែងមហោស្រពទៅ គេមានសម្ពួសខ្ចកសប្បាយ ឃើញផ្លូវរត់រលេញប្រវែង ១៥០ ម៉ែត្រ ៗ បន្ទប់ធំសឹងភ្លឺផ្លេកដោយកញ្ចក់ផ្លុះ ៗ បន្ទប់ភោជនីយ៍ប្រវែង៩០ម៉ែត្រសឹងរលេកស្មើកញ្ចក់បីដូចជាវាំងមួយពាន់

មួយយប់ ៗ ឧទ្យានមានរុក្ខជាតិពីប្រទេសក្រៅនិងសួនសត្វសំរាប់មើលកំសាន្ត ។

កប៉ាល់នេះជាទីក្សាន្តកិរម្យសមមាឌុសមដំឡៃបន្ទប់តូចធំគ្រប់កន្លែងត្រង់ណាក៏ដោយថ្លៃចរទាំងអស់ ៗ កប៉ាល់ន័រម៉ង់ឌីជាគ្រឿងអណ្ដែតពិតសំរាស់ទៀវទ្យារដោយអ្នកជិះ ២ ពាន់នាក់និងអ្នកត្រួតត្រាជាច្រើននិងពួកបំណុះ ១៣០០ នាក់បំភ្លឺដោយបង្កើនអគ្គិសនី ៤០ ពាន់ ៗ កប៉ាល់ន័រម៉ង់ឌីជាមហានាវាសមុទ្រកើតឡើងអំពីថ្វីដៃនៃបំណោះប៉ុវាកំងរំសេស ៗ

**ពាក្យពន្យល់** យក្សកប៉ាល់ = កប៉ាល់ធំក្រៃលែង ៗ មាឌុប្បមាត្រ = ទំហំ ៗ គុម្ពយន្ត = មេម៉ាស៊ីន ៗ មសញ្ញា = កណ្ដឹងសំរាប់ប្រាប់ហេតុគ្រោះ ៗ មួយពាន់មួយយប់ = ឈ្មោះរឿងស្ដេចនៅប្រទេសអារាប់ ៗ

---

## មជ្ឈិមដ្ឋានទី ២

### ផ្ទះដើរ

ព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់បង្គាប់ឲ្យធ្វើផ្លូវថ្នាយ៉ាងល្អពីមុខវាំងទៅ ប៉ុន្តែតាមសំដៅផ្លូវនោះមានផ្ទះជាងដេរអម្ពរពស្ត្រា ដែលនៅជាទំនាស់ផ្ទុ

ហើយជាងនោះមិនព្រមលក់ផ្ទះនោះសោះ ៗ មហាក្សត្រិយ៍ទ្រង់គំនិត នឹងធ្វើដូចម្ដេចឲ្យផ្ទះនោះបាត់ពីថ្លាចេញ ៗ

ដោយឃើញថាក្នុងផ្ទះនោះជាងដេរនៅតែម្នាក់ឯង ស្ដេចក៏ឲ្យទៅហៅជាងដេរមកបង្គាប់ឲ្យធ្វើអម្ពរមួយសំពត់ ហើយប្រាប់ថាយើងត្រូវការប្រញាប់ណាស់ ចូរអ្នកឯងអាស្រ័យដំណេកបាយទឹកនៅនេះចុះ លុះធ្វើអម្ពររួចហើយ យើងឲ្យថ្លៃស្របសមទៅផ្ទះចុះ ៗ ជាងដេរក៏ចាប់កាត់ដេរអម្ពរតាមសញ្ញា ៗ ជាងដេរក៏កំពុងកាត់ដេរ ស្ដេចប្រើឲ្យគេវាស់ទំហំផ្ទះជាងដេរ ហើយឲ្យរុះរូបសង់ឡើងវិញនៅកន្លែងមួយចំ-ងាយមួយរយម៉ែត្រអំពីផ្លូវ ឲ្យរៀបចំវិញដូចដែល របស់អ្វីៗក្នុងផ្ទះតាមកន្លែងដើម ការរើផ្ទះនឹងសង់ឡើងវិញ ក៏ហើយស្រេចព្រមគ្នានឹងការដេរអម្ពរពស្ត្រាភរណ៍ក៏រួចស្រេច ៗ ក្នុងពេលាយប់ងងឹត ស្ដេចប្រទានថ្លៃអម្ពរ រួចឲ្យជាងដេរទៅផ្ទះរបស់ខ្លួនវិញ ៗ មើលហ្ន៎! មនុស្សនោះដើរតាមផ្លូវថ្លា ដើរទៅៗ ទើបពិតផលថា. ដូចម្ដេចក៏ក្រៃទៅដល់ផ្ទះម្ល៉េះ ដើររហូតដល់ផុតផ្លូវ ទើបត្រឡប់មកវិញទាំងស្មានៗ រកផ្ទះតែមិនឃើញសោះ នោះប្រទះឃើញឯនាយឆ្ងាយពីថ្លា ផ្ទះមួយដូចជាផ្ទះរបស់ខ្លួន មនុស្សនោះដើរចូលទៅ ក៏ឃើញទ្រព្យសម្បត្តិទាំងអស់ ជាងដេរគិត

ជាតិអាក្រទេព្រក្សលេងកលនឹងអញតើ ។ កាលណាបើដឹងដំណើរ ហើយទើបខឹងរន្ធត់ ក៏ទៅប្ដឹងចៅក្រម នឹងទៅសារទុក្ខដល់ព្រះរាជា ប៉ុន្តែ គេមិនស្ដាប់បុរសនោះ ព្រះរាជាក៏បានផ្លូវផ្កាមានផ្លែស្រឡះល្អទៅហោង ។

ពាក្យពន្យល់ .–

ផ្លូវ ឬ មាគ៌ា; មគ្គុទ្ទេសក៍= គឺអ្នកនាំផ្លូវ; ផ្លូវហៅវិថីក៏បាន ដូចជាវិថីព្រៃនគរ, វិថីអូយេ ឯផ្លូវធំៗ គេហៅមហាវិថី ។

ជាងអម្ពរពស្ត្រា= ជាងដេរកាត់សម្លៀកបំពាក់ ពាក្យពស្ត្រាភរណ៍ ដូចគ្នានឹងពាក្យអម្ពរពស្ត្រាដែរ ។

ពិផល = ទឹកធ្វល់កង្កបិត្ត

ទេព្រក្ស = មកពី ទេវរក្ស=ទេវតាដែលរក្សា ។

លេងកល = បំភាន់ធ្វើឲ្យបង្វែងភ្នែក ។

## សេចក្ដីខុសឆ្គងបន្តិចបន្តួច

ចូរយើងកុំមើលងាយសេចក្ដីខុសឆ្គងបន្តិចបន្តួច ។ កំហុសឆ្គាំឆ្គង នេះយូរទៅមិនអាចធ្វើឲ្យវិនាសបានឡើយ ។ ប្រែះចាប់ហូតដល់ចុង រដែក ដែលជ្រលក់ទឹកក្រឡៃយ៉ាងចំណាប់ ។ ខ្យងសោកបានធ្វើឲ្យប្រះ·

ទេសហុល្លន៍ដ៏មានភ័យម្ដងហើយ ដោយពោះថ្នល់បន្ទាយទឹកដែលជាការមាំបំផុតក្នុងលោក ។ សេចក្ដីឆ្គាំឆ្គងសឹងជាដើមអាទិ៍នៃកំហុសដកប ។ អំពើពុតពាលនោះឯងដែរ ក៏ជាកូននៃសេចក្ដីឆ្គាំឆ្គង ។ ចំណុចខ្មៅតូចកើតលើធ្មេញមួយវាមិនធ្វើទុក្ខអ្វីទេ តែបើអ្នកមិនឲ្យពេទ្យមើលធ្មេញអ្នកនឹងខូចទាំងមូលពុំលែង ហើយបើអ្នកមិនឲ្យដកយកចេញ ធ្មេញឯទៀតនឹងខូចតាមគ្នាទាំងអស់ ។ សេចក្ដីធ្វេសក្លាយទៅជាអំពើឆ្គាំឆ្គង ។ អំពើឆ្គាំឆ្គងនោះមិនតូចតាចណាស់ទេ ព្រោះអំពើនោះលាក់ទុកកំហុស ។ កាលណាអ្នកធ្វើខុសអ្វីមួយ ហើយអ្នកមិនហ៊ានប្រាប់គេ នោះគេនរណាលាក់ទុកគឺសេចក្ដីធ្វេសនោះឯង ។ កុហកជាបុត្រជិតជិតរបស់ក្ដីធ្វេស តែក្ដីធ្វេសនោះពុំមែនមានតែកូនមួយប៉ុណ្ណោះឡើយ ។ តាមដោយពិចារណាខ្ញុំឃើញមានកូនពីរអាក្រក់ដូចគ្នា គឺឥស្សាមួយ និងឈ្នានីសមួយ ទាំងពីរនេះកើតទៅជាគំនុំគុំគួនដែលជាមេនៃគរុទោស ។

ចូរអ្នកមានអធ្យាស្រ័យដល់កំហុសបន្តិចបន្តួចរបស់មិត្តសំឡាញ់អ្នក បើអ្នករំឭកពុំបានតែកំហុសចំពោះខ្លួនអ្នកវិញ ចូរអ្នកប្រឹងជំនះលុះត្រាតែឈ្នះ ។

ពាក្យពន្យល់ .–

ឆ្គាំឆ្គង= មិនប្រព្រឹត្តកិច្ចប្រតិបត្តិតូចតាច ដូចជាមិនបានបើកមួកនឹងគ្រូជាដើម ។

ប្រែះ= គឺស្នឹមដែលកើតលើដែក ។

ឆ្មើង= គឺសេចក្ដីមើលងាយថាគេទាបជាងខ្លួន គឺខ្វះការគោរពតាមសការៈខ្ពស់ទាប ។

ឥស្សា= ចិត្តខ្នាញ់ទឹងឃើញគេខ្ពស់លើសខ្លួន ។

ឈ្នានីស= សេចក្ដីប្រឹងប្រែងធ្វើឲ្យគេវិនាសទៅ ។

គរុទោស= ទោសធ្ងន់គឺ ឧក្រិដ្ឋ; មជ្ឈិមទោស= ទោសយ៉ាងកណ្ដាល;

លហុទោស= ទោសល្មើសបន្តិចបន្តួច ។ ទោសលោកសង្ឃហៅ-អាបត្តិ ។

---

# មជ្ឈិមដ្ឋានទី១

## រឿងបបកនឹងដំរីស្ដ

នៅក្នុងព្រៃធំ, មានដំរីស្ដមួយឈ្មោះ គបុរិតិលកៈ ។ សត្វបចក មួយហ្វូងធំ ឃើញដំរីស្ដនោះ ក៏គិតគ្នាថា: "បើយើងប្រើឧបាយកលណា

មួយសម្លាប់ដំរីនេះបាននោះ មុខជាយើងនឹងបានសាច់វាជាចំណីអាហារចំ-អែតផ្ទៃអស់កាលកំណត់បួនខែ" ។

បណ្ដាចចកទាំងឡាយនោះ មានចចកមួយយកអាសា និយាយអួតអាង ថា៖ "ដោយអានុភាពប្រាជ្ញខ្ញុំ ខ្ញុំមានកិច្ចកលវិសេសមួយ អាចសម្លាប់ដំរីស្ដេចនេះឲ្យបាន"

លំដាប់នោះចចកចាស់ធោក ដើរចូលទៅរកដំរីស្ដេចនោះ ធ្វើកិរិយាឱនលំទោន លុតក្រាប ពោលពាក្យជាទីគោរពថា៖ "បពិត្រលោកជាស្ដេចដំរី សូមលោកមេត្តាប្រោស ខ្ញុំបាទសូមជួបនឹងលោក" ។ ដំរីស្ដេចសួរទៅវិញថា៖ "ឯងជាអ្វី ឯងទៅណាមកណា រកអ្វីហ្នឹង?"

ចចកក៏ឆ្លើយប្រាប់ថា៖ ខ្ញុំបាទជាសត្វចចក, ឥឡូវនេះ ពួកចតុប្បាទទាំងឡាយ តែងអាស្រ័យនៅនាព្រៃ ប្រជុំព្រមព្រៀងគ្នា មូលមតិស្របហើយ ទើបចាត់ឲ្យខ្ញុំចូលមកក្រាបបង្គំទូលព្រះអង្គថា៖ "ការនៅមិនមានស្ដេចគ្រប់គ្រងថែរក្សា មិនបានសេចក្ដីសុខទេ សូមអញ្ជើញព្រះអង្គធ្វើជាស្ដេច ហើយនឹងគិតគូរអភិសេក សោយរាជ្យនៅនាព្រៃនេះ ព្រោះព្រះអង្គប្រកបដោយស្វាមីគុណសព្វគ្រប់ប្រការ សមគួរជាស្ដេចគ្រប់គ្រងសត្វចតុប្បាទទាំងឡាយដែលនៅក្នុងដីនេះ" ។ បើដូច្នោះសូមទ្រង់កុំបង្អង់

ឲ្យយឺតយូរ សូមអញ្ជើញទៅដោយរួសរាន់ឲ្យទាន់ពេលវេលា ជាមង្គលសិរីសួស្តី និយាយដូច្នោះហើយក៏នាំដំរីនោះដើរទៅ ។

ឯដំរីស្តឈ្មោះកបុរិតិលកៈ លុះក្នុងអំណាចលោភធម៌ ចង់បានរាជ-សម្បត្តិ ចាញ់កលបបក ស្រវឹងយសក្រោយខ្លួន ខំដើរតាមបបកយ៉ាងលឿន ទៅផុងលង់ក្រទេសក្នុងបឹងភក់ជាប់ទៅទៀតមិនរួច ទើបស្រែកហៅបបកឲ្យជួយស្រង់ ។ បបកបានសមបំណងធ្វើជាអស់សំណើចសើចហាសហាយ និយាយចំអកឡកឡឺយថា: "ទេវៈ" សូមលោកមេត្តាយកប្រមោយតោងចុងកន្ទុយខ្ញុំឲ្យជាប់ខ្ញុំនឹងខំព្រយុងឲ្យឡើងរួច; ដោយអំពើដែលលោកជឿស្តាប់ពាក្យខ្ញុំនេះ សូមលោកសោយរាជ្យនូវសេចក្តីទុក្ខនេះចុះ ។

លំដាប់នោះ, បបកទាំងឡាយនាំគ្នាហែកដែញ្ជដំរីស្តដែលផុងក្នុងភក់ជ្រៅ ស៊ីជាអាហារក្នុងគ្រានោះឯង ។

ពន្យល់ពាក្យ.—

បបក = ឈ្មោះសត្វជើង ៤ សន្តានឆ្កែព្រៃ ។ ដំរីស្ត = ដំរីឈ្មោល គ្មានភ្លុក មានតែថៃ ។ យកអាសា = ជួយឈឺឆ្អាលដោយស្ម័គ្រស្មោះ អស់ពីចិត្តពីថ្លើម ។ អភិសេក (អានថា: អ ភិ សេកកៈ)= ការស្រោច

ទឹកកួស់ទឹកស័ទ្ធ ៗ ស្វាម៉ិគុណ = គុណប្រកបដោយលក្ខណៈជាម្ចាស់ ៗ លោភធម៌ = (ម.ថ. លោភៈ ធ៌រ) សភាវៈប្រកបដោយសេចក្ដីជំពាក់ចិត្ត ៗ លង់ទ្រនេស = ជួលដេកជាប់ក្រោកទៅណាពុំរួច ៗ សមបំណង = បានដូចបំណង: ដែលត្រូវត្រង់តាមបំណង ៗ ហែកជញ្ជ្រង = ខាំ, ហែកប្រ-ដែងគ្នា ៗ

---

# អានិកខ្លាន

## បង្រៀនពាក្យនឹងភាសា

### អាទិត្យទី ១ — អំពីពេលវេលា

នាម — ថ្ងៃ យប់ អាទិត្យ ខែ ឆ្នាំ មួយពេល មួយស្របក់ ម៉ោង នាទី មីនុត ៗ

គុណនាម — ភ្លឺ ងងឹត យូរ ឆាប់ រហ័ស ឆ្នាំចាស់ ឆ្នាំថ្មី ខែ ខែមុន ខែក្រោយ ដើមខែ ចុងខែ... ៗ

កិរិយាសព្ទ ខាតពេលវេលា កត់ខែ ថ្ងៃ ឆ្នាំ រាប់ខែ ថ្ងៃ ឆ្នាំ មើលម៉ោង .— មីនុត ថ្ងៃរះ ថ្ងៃលិច ថ្ងៃតាំង

ហាត់ភាសា .- ដែលហៅថាពេលវេលានោះគឺអ្វី ? ក្នុង ១ ឆ្នាំមានប៉ុន្មានខែ ? គឺខែអ្វីខ្លះ ? ខ្មែរយើងរាប់ឆ្នាំជាប៉ុន្មាន ? គឺឆ្នាំអ្វីខ្លះ ? ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ ? គឺថ្ងៃអ្វីខ្លះ ? ក្នុងមួយខែមានប៉ុន្មានថ្ងៃ ? ក្នុងមួយថ្ងៃមួយយប់ប៉ុន្មានម៉ោង ?

## បង្រៀនមើល

## អំពីពេលតាមរបៀបខ្មែរ

( សៀវភៅវត្ថុស្ថាពព្រាយន៍បរិច្ចណដ្ឋានទំព័រ១០៨ )

កែដម្រូវ – អាសុជ្ឈ = អស្សុជ ។ បឋមសាឍ = បឋមាសាឍ ។

## សរសេរតាមសូត្រ

## អំពីពេលវេលា

ដែលហៅថាពេលវេលានោះ គឺគេសម្រេចយកតាម កំណត់ដំណើរព្រះធរណីវិលជុំវិញខ្លួនឯង ហើយនឹងវិលក្រឡឹងជុំវិញព្រះ

អាទិត្យផង ៗ ពេលដែលព្រះធរណីវិល បានមួយជុំខ្លួនឯងនោះ ហៅថាមួយថ្ងៃមួយយប់គឺម្ភៃបួនម៉ោង លុះព្រះធរណីវិលបានមួយជុំព្រះអាទិត្យ ទើបហៅថាមួយឆ្នាំ មួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ឬហាសិបពីរអាទិត្យ ៗ

ដែលហៅថារដូវនោះ គឺក្នុងកំឡុងដែលខ្យល់អាកាសផ្លាស់ប្ដូរគ្នាក្នុងមួយឆ្នាំ ៗ ៗ

សរសេរពាក្យពិបាក : ដំណើរ - ព្រះធរណី - ព្រះអាទិត្យ - ម្ភៃ - ហុកសិបប្រាំ - ហាសិបពីរ ខ្យល់ ផ្លាស់ប្ដូរ

## តែងសេចក្ដី ១

ចូរអ្នកអធិប្បាយអំពីអ្នកប្រើពេលវេលាដូចម្ដេចខ្លះ តាំងពីព្រលឹមរហូតដល់ព្រលប់ ៗ

### ទំនង់តង់

តាំងពីព្រលឹមរហូតដល់ពេលបាយ អ្នកធ្វើអ្វីខ្លះ ? ចុះពេលល្ងាចទល់ទឹងព្រលប់អ្នកធ្វើអ្វីទៀត ? ៗ

## អក្សរផ្ចង់

## បង្រៀនសរសេរអក្សរ "មូល"

### អាទិត្យទី ២.- អំពីខ្យល់

នាម – ខ្យល់ ខ្យល់រំភើយ ខ្យល់ដំនោរ ខ្យល់ព្យុះ ព្យុះសង្ឃរា ខ្យល់កំបុតត្បូង ( ខ្យល់គួច ) ខ្យល់ពីងដើង ៗ

គុណនាម -- រហើយត្រសៀក ត្រជាក់ រងា តិច ខ្លាំង រំភើ

កិរិយាសព្ទ – ខ្យល់បក់តិចៗ ខ្យល់បក់ខ្លាំង ខ្យល់គួចធូលី ខ្យល់រំលំរលើងដើមឈើ បង្ហើរខ្លែង បើកក្ដោង ៗ

## បង្រៀនមើល

### ខ្យល់បក់មកពីទិសខាងជើង

សៀវភៅរដ្ឋខេមរភាសាបរិវច្ឆណដ្ឋាន ទំព័រ ៦៤ មេរៀនទី៤៣

# សរសេរតាមសូត្រ

## អំពីខ្យល់

កាលណាយើងឈរឬអង្គុយនៅកណ្ដាលទីវាល ហាក់ដូចជាមានធម្មជាតិអ្វីមកប៉ះពាល់ខ្លួនយើងឲ្យល្ហើយ ធម្មជាតិនេះហៅថាខ្យល់ ។ ឯស្លឹកឈើដែលកំរើកទៅមកបាន នោះគឺខ្យល់បក់ ។ ខ្យល់បក់នេះជួនខ្លាំង ជួនតិច ខ្យល់បក់តិច ៗ ហៅថាខ្យល់ដំនោរ ខ្យល់បក់ខ្លាំងហៅថាព្យុះ កាលណាខ្យល់នោះបក់ខ្លាំងអស្ចារ្យ ហៅថាព្យុះសង្ឃរា ។

ខ្យល់ព្យុះអាចធ្វើឲ្យដើមឈើ ផ្ទះសំបែង ទូក កប៉ាល់ វិនាសអន្តរាយបាន ។

ខ្យល់មានប្រយោជន៍ ដើម្បីឲ្យអ្នកដើរ ទូក សំពៅ បើកក្ដោង លឿនទៅបានដោយងាយ ។

សរសេរពាក្យពិបាក – ធម្មជាតិ (អានថាធម មៈជាត) ខ្យល់ – ល្ហើយ វាល – ព្យុះសង្ឃរា – វិនាស អន្តរាយ – អស្ចារ្យ – កប៉ាល់ – លឿន ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីខ្យល់ព្យុះតាមពាក្យចោទខាងក្រោមនេះ ៖

យ៉ាងដូចម្ដេចដែលហៅថាខ្យល់ព្យុះ ? – នៅក្នុងរដូវណាដែលមានខ្យល់ព្យុះ ? – ខ្យល់នោះបក់មកពីទិសឯណា ? – មុននឹងមានខ្យល់នោះ អ្នកសំគាល់ឃើញមានហេតុអ្វីនៅលើមេឃ ? – វេលាខ្យល់នោះបក់មក អ្នកឮសូរដូចម្ដេចខ្លះ ? – អ្នកឃើញមានអ្វីមកជាមួយផង ? អ្នកឃើញខ្យល់នោះបណ្ដាលឲ្យមានហេតុអ្វីខ្លះ ? – នៅក្នុងភូមិអ្នក – នៅក្នុងទន្លេ ? – អ្នកចូលចិត្តនឹងខ្យល់នោះឬទេ ? ព្រោះអ្វី ? ។

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ៣ ._ អំពីភ្លៀង ឥន្ទធនូ

នាម ._ ភ្លៀង ផ្គរ រន្ទះ ផ្លេកបន្ទោរ ឥន្ទធនូ សន្សើម គ្រាប់ភ្លៀង ទឹកភ្លៀង ។

គុណនាម .– ច្រើន តិច ស្រិចៗ ប្រុយៗ រលឹម ទទឹក ជោក សើម ។

កិរិយាសព្ទ .– រាំងភ្លៀង ភ្លៀងស្រក់តក់ៗ ទឹកភ្លៀងដក់ ទឹកភ្លៀងជ្រាបទៅក្នុងដី ត្រងទឹកភ្លៀង ងូតទឹកភ្លៀង ។

## អំពីនាឡិកា

នាម .– នាឡិកាយោល នាឡិការោទិ៍ នាឡិកាដក់ ផ្ទះនាឡិកា គ្រឿងនាឡិកា ខ្សែឡាន កូនសោ ប៉ោល ទ្រនិច លេខ កញ្ចក់ យ៉ៃ ។

គុណនាម .– ទៀង យឺត លឿន គាំង ខូច ដាច់ឡាន ថ្មី ចាស់ ។

កិរិយាសព្ទ .– មួលនាឡិកា ផ្ទៀងនាឡិកា ប្ដូរ ម៉ោង បង្វិលទ្រនិច មើលម៉ោង នាឡិកាដើរ នាឡិកាឈប់ (ឆាប់)

## សរសេរតាមសូត្រ

### ភ្លៀង

ទឹកភ្លៀងបង្កើតមកអំពីពពក ឯពពកកើតឡើងអំពីចំហាយទឹកនៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ប្រមូលផ្តុំគ្នាឡើងហើយអណ្តែតទៅព-

ដីអាកាស កាលណាពពកនោះរសាត់ទៅប្រទះនឹងខ្យល់ត្រជាក់ខ្លាំងក៏កក ទៅជាទឹក ហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសំពប់ ចិញ្ចឹមរុក្ខជាតិទាំងឡាយ ឬផ្តុំគ្នាកើតបានជាដង្ហើមទឹក មួយចំណែកទៀត ហូរធ្លាក់ទៅក្នុងថ្លុក ត្រពាំង បឹង ស្ទឹង ទន្លេ សមុទ្រ ។ កាលណាមាន ភ្លៀងច្រើនតែងមានព្យុះ ផ្គរ ផ្លេកបន្ទោរ ហើយទឹងរន្ទះផង ។

ពាក្យពិបាក ៖ – ផ្តុំ អណ្តែត រសាត់ រុក្ខជាតិ ព្យុះ ផ្គរ ផ្លេក-បន្ទោរ ។ (ភ្លៀងសរសេរបានពីរយ៉ាង "ភ្លៀង ឬ ផ្លៀង") ។

## តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីថ្ងៃមួយដែលមានភ្លៀងមួយមេយ៉ាងធំ ។ អ្នកបានឃើញដូចម្តេចខ្លះ នៅវេលាមុនភ្លៀង វេលាកំពុងភ្លៀង វេលាក្រោយភ្លៀង ? យោបល់របស់អ្នក ? ។

## សេចក្តីអធិប្បាយជាគំរូ

(យកតាមសេចក្តីក្នុងទស្សនាវដ្តីឆ្នាំទី ១ លេខ ៩ ទំព័រ ១៧ )

### អាទិត្យទី ៤.-

សូមសួរសារបង្រៀនតាំងពីដើមឡើងវិញ ។

# ក្ខុហារដ្ឋាន

## រៀនពាក្យនិងភាសា

### អាទិត្យទី ១.– អំពីភូមិ

នាម.- ភូមិ, ក្រុង, ផ្លូវធ្លា, ផ្ទះ, សាលារៀន, សាលាឃុំ, ទន្លេ, ព្រែក, បឹង, របង, ទ្រុងជ្រូក, ក្រោលគោ ក្របី, ដើមពោធិ៍, ដំណាំ, ចេក, ត្របែក, ក្រូច, ម្នាស់, ខ្នុរ, ស្វាយ, ដូង, ស្លា, ត្នោត, អំពិល, កន្ទួត, សណ្ដាន់, ក្រសាំង, ខ្វិត, វាលស្រែចំការ,

គុណនាម.– ឆ្ងាយ, ជិត, ធំ, ទូលាយ, ខ្ពស់, ទាប, ស្អាត កខ្វក់, ច្រើន, តិច, ស្អុយ, ផ្អែម, ឆ្អាប ។

កិរិយា.– ដើរកាត់ទៅភូមិ, ចេញពីភូមិ, ចូលក្នុងក្រុងធំ, សង់ផ្ទះ, ដាំចេក, បោសសំអាតភូមិ, កាប់ឈើ, ធ្វើក្រោលក្របី, រុះរើទ្រុងជ្រូក, ដាក់ជីចំពេញថ្លុក, បុកពង្រាបដីភូមិ ។

ភាសា-- ភូមិអ្នកឈ្មោះភូមិអ្វី ? ភូមិនោះនៅខាងណាទីក្រុង ? ឆ្ងាយឬជិត ? ភូមិនោះធំឬតូច ? បណ្ដៀតឬទូលាយ ? នៅភូមិនោះ

មានផ្ទះច្រើនឬតិច ? ផ្ទះសង់ខ្ពស់ឬទាប ដំបូលប្រក់អ្វី ? ផ្ទះអ្នកនៅឆ្ងាយឬជិតសាលាឃុំ ? នៅភូមិអ្នកមានសាលារៀនឬទេ ? មានដើមឈើនិងដំណាំអ្វីខ្លះនៅក្នុងភូមិអ្នក ?

## អាទិត្យទី ២.- អំពីវត្ត

នាម.- ទីធ្លា, កំពែង, របង, ខ្លោងទ្វារ, ទេន្ទ, ផ្លូវធ្លា, ដើមឈើ, ព្រះវិហារ, កុដិ, សាលា, ព្រះចេតិយ, កំពូល, ពេនទូក, ខ្ទមអ្នកតា, ពនទេវតា, អាស្រម, ផ្ទះដូនជី, ក្បាច់រចនា, ដើមផ្កា ព្រះពុទ្ធរូប, លោកសង្ឃ, ឧបាសក, តាយក ។

គុណនាម.- ធំ, ទូលាយ, ស្អាត, ល្អ, រលើប, ខ្ពស់, ទាបរាបស្មើ, ស្រួល, រុងរឿង, ថ្កុំថ្កើង, ទ្នោលប្រាលផ្អៅ, ឆ្ងាយ, ជិត, ត្រសុំ, ត្រសាយ, ក្រអូបឈ្ងុយឈ្ងប់, ទ្រហឹងអឹងកង, ក្តីព្រោងព្រាត, ស្ងាត់ឈឹង, ។

## ភាសា.-

សុំគ្រូតែងពាក្យចោទសួរសិស្សតាមរបៀបដែលយើងបានធ្វើអាទិត្យទី ១ នឹងចុះ ។

## អាទិត្យទី៣ និងទី៤.- អំពីក្រុង

នាម.- ផ្សារ, ផ្លូវថ្នល់, ទន្លេ, ព្រែក, ស្ពាន, ថ្លុក, ត្រពាំង, ផ្ទះផ្សារ, ផ្ទះលក់ទំនិញ, គេហស្ថាន, វត្តលោក, វាំង, សាលារៀន, រោងម៉ាស៊ីន, រោងរងទង, ជាងដែក, ជាងឈើ, សាលារចនា, បង្កៀង គោមអគ្គិសនី, យានជំនិះផ្សេងៗ, ជនានុជន, ប្រដាប់ស្លៀកពាក់, ប្រដាប់ប្រើប្រាស ។

គុណនាម.- រុងរឿង, ថ្កុំថ្កើង, ល្អ, អាក្រក់, ស្អាត, ក្រខ្វក់ ធំទូលាយ, ខ្ពស់, ស្រឡះ, សម្បើម, មាំ, ស្រួច, វែង, សុខក្សេម-ក្សាន្ត, ជិត, ឆ្ងាយ, ក្រហេងក្រហូង, រាបស្មើ, ច្រើនពោរពាស, ខ្វាត់ខ្វែង, ឈ្ងូរឆ, ទ្រហឹងអឺងកង, បង្អៀតគាន់គាប, រំពងខ្ទរខ្ទា, គ្រឹកគ្រេង, ។

កិរិយា.- រៀបចំទីក្រុង, ចាក់ដី, លុបថ្លុកត្រពាំង, យកខ្សាច់, រីគ្រួស, ធ្វើស្ពាន, សង់ផ្ទះ, ដើរលេងផ្សារ, លក់ទំនិញ, ទៅទិញ ពត់, ជិះរទេះ, ឆ្លងកាត់ព្រែក, ចូលក្នុងផ្សារ, ដើរត្រួតត្រា, ឈរយាមល្បាត, បោសថ្នល់, គើបសំរាម, បង្ហូរទឹកសំអុយ

## បង្រៀនមើល

អាទិត្យទី ១ .– មេឃុំនៅភូមិយើង

*(សៀវភៅវិជ្ជាខេមរភាសាបរិវត្ត. ទំព័រ ៨២)*

អាទិត្យទី ២ .– អ្នកយាមល្បាតនៅក្នុងភូមិ

*(សៀវភៅដដែល ទំព័រ ៨៤)*

អាទិត្យទី ៣ នឹងទី៤.– ព្រះវិហារព្រះកែវមរកតនៅក្រុងភ្នំពេញ

*(សៀវភៅដដែល ទំព័រ ១០៩)*

---

# បរិទ្ធណភដ្ឋាន

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ១.– អំពីពេលវេលា

*នាម.– ថ្ងៃ, យប់, អាទិត្យ, ខែ, ឆ្នាំ, មួយរំពេច, មួយស្របក់, ម៉ោង, នាទី, (មីនុត) ។*

គុណនាម.— ភ្លឺ, ងងឹត, យូរ, ឆាប់, ឆ្នាំចាស់, ឆ្នាំថ្មី, ខែមុន, ខែក្រោយ, ដើមខែ, ចុងខែ, កណ្តាលខែ ។

កិរិយា.— ខាតពេលវេលា, កត់ថ្ងៃខែឆ្នាំ, មើលម៉ោង, ថ្ងៃរះ, ថ្ងៃលិច, ថ្ងៃតាំង ។

ភាសា.— ដែលគេហៅថាពេលវេលានោះគឺអ្វី? ក្នុង ១ ឆ្នាំមានប៉ុន្មានខែ? គឺខែអ្វីខ្លះ? ឯឆ្នាំគឺឆ្នាំអ្វីខ្លះ? ក្នុង ១ អាទិត្យមានប៉ុន្មានថ្ងៃ? គឺថ្ងៃអ្វីខ្លះ? ក្នុង ១ ខែមានប៉ុន្មានថ្ងៃ? ក្នុង ១ ថ្ងៃ ១ យប់មានប៉ុន្មានម៉ោង?

## អាទិត្យទី ២.— អំពីខ្យល់

នាម.— ខ្យល់, ខ្យល់រំភើយ, ខ្យល់ដំនោរ, ខ្យល់ព្យុះ, ព្យុះសង្ឃរា, ខ្យល់កំបុតត្បូង (ខ្យល់គួច), ខ្យល់ពីងដើន ។

គុណនាម.— រហើយត្រសៀក, ត្រជាក់, រងា, តិច, ខ្លាំង, រក់រី ។

កិរិយា.— ខ្យល់បក់តិចៗ, ខ្យល់បក់ខ្លាំង, ខ្យល់គួចក្បួល, បង្ហើរខ្លួន, បើកក្តោង ។

## អាទិត្យទី ៣.— អំពីភ្លៀង-ឥន្ទធនូ

នាម.— ភ្លៀង, ផ្គរ, រន្ទះ, ផ្លេកបន្ទោរ, ឥន្ទធនូ, សន្សើម, គ្រាប់ភ្លៀង, ទឹកភ្លៀង ។

គុណនាម.- ច្រើន, តិច, ស្រិចៗ, ប្រុយៗ, រលឹម, ទទឹកជោក, សើម ។

កិរិយា.- រាំងភ្លៀង, ភ្លៀងស្រក់តក់ៗ, ទឹកភ្លៀងដក់ ទឹកភ្លៀងជ្រាបទៅក្នុងដី, ត្រង់ទឹកភ្លៀង, ងូតទឹកភ្លៀង ។

## អាទិត្យទី ៤.- អំពីនាឡិកា

នាម.- នាឡិកា ឬ នាលិកា, នាឡិកាយោល, នាឡិកាពេទ៌ នាឡិកាដក់, ផ្ទះនាឡិកា, គ្រឿងនាឡិកា, ខ្សែឡាន, កូនសោ, ប៉ោល, ទ្រនិច, លេខ, កញ្ចក់, យ៉ៃ ។

គុណនាម.- ទៀង, យឺត, លឿន, គាំង, ខូច, ដាច់ឡាន, ថ្មី, ចាស់ ។

កិរិយា.- មួលនាឡិកា, ផ្ទៀងនាឡិកា ឬ ម៉ោង, បង្វិលទ្រនិច, មើលម៉ោង នាឡិកាដើរ, នាឡិកាឈប់ (ច្រើនថានាឡិកាងាប់) ។

## បង្រៀនមើល

## អាទិត្យទី ១.- អំពីពេលតាមរបៀបខ្មែរ

(សៀវភៅវត្ថុស្វាធ្យាយន៍ បវរ. ទំព័រ ១០៨)

## សរសេរតាមសូត្រ

### អំពីពេលវេលា

ដែលហៅថាពេលវេលានោះគឺ គេសម្រេចយកតាមកំណត់ដំណើរព្រះធរណីវិលជុំវិញខ្លួនឯង ហើយនិងវិលក្រឡឹងជុំវិញព្រះអាទិត្យផង ។ ពេលដែលព្រះធរណីវិលបានមួយជុំខ្លួនឯងនោះ ហៅថាមួយថ្ងៃមួយយប់ គឺម្ភៃបួនម៉ោង លុះព្រះធរណីវិលបានមួយជុំព្រះអាទិត្យ ទើបហៅថាមួយឆ្នាំ មួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ឬ ហាសិបពីរអាទិត្យ ។

ដែលហៅថារដូវនោះ គឺកន្លងកំឡុងដែលខ្យល់អាកាសផ្លាស់ប្ដូរគ្នាក្នុង ១ ឆ្នាំ ៗ ។

សរសេរពាក្យពិបាក .– ដំណើរ, ព្រះធរណី, ព្រះអាទិត្យ, ម្ភៃ ហុកសិបប្រាំ, ហាសិបពីរ, ខ្យល់, ផ្លាស់ប្ដូរ ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីអ្នកប្រើពេលវេលាដូចម្ដេច តាំងពីព្រលឹមឡើងរហូតដល់ព្រលប់ ។

## ទំនងតែង

តាំងពីព្រលឹមរហូតដល់ពេលបាយអ្នកធ្វើអ្វីខ្លះ ? ចុះពេលល្ងាចទល់នឹងព្រលប់អ្នកធ្វើអ្វីទៀត ?

## បង្រៀនមើល

### អាទិត្យទី ២ .- អំពីខ្យល់បក់មកពីទិសខាងជើង

សៀវភៅខេមរភាសា បរិ. ទំព័រ ៦៤

## សរសេរតាមសូត្រ

### អំពីខ្យល់

កាលណាយើងឈរឬអង្គុយនៅកណ្ដាលទីវាល ហាក់ដូចជាមានអ្វីមកប៉ះពាល់ខ្លួនយើងនាំឲ្យល្ហើយ នេះហៅថាខ្យល់ ។ ឯស្លឹកឈើដែលកំរើកទៅមកបាន នោះគឺខ្យល់បក់ ។ ខ្យល់បក់នេះដួនខ្លាំង ដួនតិច ខ្យល់បក់តិចៗ ហៅថាខ្យល់ដំនោរ ខ្យល់បក់ខ្លាំងហៅថាព្យុះ កាលណាខ្យល់នោះបក់ខ្លាំងអស្ចារ្យហៅថាព្យុះសង្ឃរា ។

ខ្យល់ព្យុះអាចធ្វើឲ្យដើមឈើ ផ្ទះសម្បែង ទូក កប៉ាល់អន្តរាយបាន ។

ខ្យល់មានប្រយោជន៍ ដើម្បីឲ្យអ្នកដើរទូក សំពៅបើកក្ដោងលឿនទៅបានឆ្ងាយ ។

សរសេរពាក្យពិបាក .– ល្ហើយ, រល, ព្យុះសង្ឃរា អន្តរាយ, អស្ចារ្យ, កប៉ាល់, លឿន ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីខ្យល់ព្យុះតាមពាក្យចោទខាងក្រោមនេះ ៖

យ៉ាងដូចម្ដេចដែលហៅថាខ្យល់ព្យុះ? នៅក្នុងរដូវណាដែលមានខ្យល់ព្យុះ? ខ្យល់នោះបក់មកពីទិសឯណា? មុននឹងមានខ្យល់នោះអ្នកសំគាល់ឃើញហេតុអ្វីនៅលើមេឃ? វេលាខ្យល់នោះបក់មក អ្នកឮសូរដូចម្ដេចខ្លះ? អ្នកឃើញមានអ្វីមកជាមួយផង? អ្នកឃើញខ្យល់នោះបណ្ដាលឲ្យមានហេតុអ្វីខ្លះ នៅក្នុងភូមិអ្នក នៅក្នុងទន្លេ? អ្នកចូលចិត្តនឹងខ្យល់នោះឬទេ? ពីព្រោះអ្វី? ។

## បង្រៀនមើល

### អាទិត្យទី ៣.– អំពីភ្លៀង

ទឹកភ្លៀងបង្កើតមកអំពីពពក ឯពពកកើតឡើងអំពីចំហាយទឹក នៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ប្រមូលផ្តុំគ្នាឡើងហើយអណ្តែតទៅលើអាកាស កាលណាពពកនោះរសាត់ទៅប្រទះនឹងខ្យល់ត្រជាក់ខ្លាំងក៏កកទៅជាទឹក ហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសំរាប់ចិញ្ចឹមរុក្ខជាតិទាំងឡាយ ឬផ្តុំគ្នាកើតបានជាដង្ហើមទឹក មួយចំណែកទៀតហូរធ្លាក់ទៅក្នុងថ្លុក ត្រពាំង បឹង ស្ទឹង ទន្លេ សមុទ្រ ។ កាលណាមានភ្លៀងច្រើន មានព្យុះ ផ្គរ ផ្លេកបន្ទោរ ហើយនឹងរន្ទះផង ។

ពាក្យពិបាក .– ផ្តុំ, អណ្តែត, រសាត់, រុក្ខជាតិ, ព្យុះ, ផ្គរ, ផ្លេក-បន្ទោរ ។ ភ្លៀងសរសេរបានពីរយ៉ាង ភ្លៀង ឬ ផ្លៀង ។

## សរសេរតាមសូត្រ

សុំគ្រូយកមេរៀនមើល "អំពីភ្លៀង" មកធ្វើជាសរសេរតាមសូត្រផងចុះ ។

## តែងសេចក្ដី

ចូរអធិប្បាយអំពីភ្លៀងតាមពាក្យបោទខាងក្រោមនេះ៖

នៅស្រុកខ្មែរយើងរដូវណាដែលមានភ្លៀងច្រើន? ភ្លៀងនោះធ្លាក់មកពីណា? វេលាមុនភ្លៀងអ្នកឃើញមានអ្វី ហើយអ្នកឮសូរអ្វីនៅលើមេឃ? នៅវេលានោះមេឃយ៉ាងដូចម្ដេច? លុះបន្តិចមកទៀតអ្នកឃើញមានអ្វីស្រក់ចុះមក ហើយហូរធ្លាក់ទៅឯណា? នៅក្នុងស្រែឬក្នុងថ្លុកត្រពាំង អ្នកឃើញមានអ្វី? នៅក្នុងរដូវនោះអ្នកស្រែបំការធ្វើអ្វីខ្លះ? ឯទឹកទន្លេឡើង-ឬស្រក? អ្នកចូលចិត្តទឹកភ្លៀងឬទេ? ពីព្រោះអ្វី?

## តែងសេចក្ដី

### អាទិត្យទី ៤.–

ចូរអ្នកអធិប្បាយអំពីនាឡិកាដក់ តាមពាក្យបោទខាងក្រោមនេះ៖

ឪពុកអ្នក ឬ គ្រូអ្នកមាននាឡិកាដក់ឬទេ? នាឡិកានោះធ្វើពីអ្វី? រាងវាយ៉ាងដូចម្ដេច? នៅខាងមុខវាអ្នកឃើញមានអ្វីខ្លះ? ឯក្រវិលនឹងកំ-

ពូលពាំសំពប់ធ្វើអ្វី? ឯទ្រនិចវាទាំងពីរប៉ុនគ្នាដែរឬទេ? ហើយវិលស្មើគ្នាឬទេ? ទ្រនិចមួយចង្អុលអ្វី? ទ្រនិចមួយទៀតចង្អុលអ្វី? បើអ្នកយកនាឡិកាដកមកដាក់ជិតត្រចៀកអ្នកឮសូរដូចម្តេច? នាឡិកាមានប្រយោជន៍ឬទេ? ពីព្រោះអ្វី? ។

---

## មជ្ឈិមដ្ឋានទី ២ និង ឧត្តមដ្ឋាន ។

នព្វន្ត - រង្វាស់ - រង្វាល់ - ភូមិសាស្ត្រ

សូមសារបង្រៀនពីដើមឡើងវិញ ។

---

# បណ្ណិបដ្ឋានទី ១

## សព្វគ្គ

## លេខចែកចែងភាគពេល

ឧបមា: ៤ ថ្ងៃ ១៣ម ៤៧មន ៥០ស ចែកនឹង ៨

```
៤ថ ១៣ម ៤៧មន៥០ស          | ៨
------------------        |------------------
២៤ថ×៤=៩៦ម                 | ១៣ម ៤៣មន ២៦ស
      ១០៩ម
       ២៩
        ៥
៦០ម×៥=៣០០មន
      ៣៤៧មន
       ២៧
        ៣
៦០×៣=១៨០
      ២៣០
       ៧០
        ៦
```

- គេសំរាយ ៤ ថ្ងៃ ទៅជាម៉ោង. ហើយគេបញ្ចូលលទ្ធផលទៅ ១៣ ម៉ោងបានជា១០៩ម៉ោងទើបយកទៅចែកនឹង ៨ ឃើញបាន ១៣ ម៉ោង នៅសល់ ៥ម៉ោង ។

-សេស ៥ ម៉ោងនេះត្រូវសំរាយឲ្យទៅជាមីនុតគឺបានលទ្ធផល ៣០០-មីនុត ។ នេះយកទៅបញ្ចូល ៤៧ មីនុតបាន ៣៤៧ មីនុតទៅចែកនឹង ៨ ឃើញបាន ៤៣ មីនុតនៅសល់ ៣ មីនុត ។

គេសំពាយ ៣ ម៉ឺនុតឲ្យទៅជាសឺកុន៍ ឃើញលទ្ធផល ១៨០ សឺកុន៍ ទើបយកលទ្ធផលនេះទៅបញ្ចូល នឹង ៥០ សឺកុន៍ ឃើញបាន ២៣០ សឺកុន៍ នៅសល់ ៦ សឺកុន៍ ។

មេរៀន .— ដើម្បីនឹងចែកលេខចំនួនបែងភាគពេលនឹងចំនួនគូមួយដុំ គេត្រូវចែកលេខដែលនៅខាងឆ្វេងដៃ គឺ លេខដែលធំជាងគេនឹងចំនួនដុំនោះ បើចែកទៅហើយមិនដាច់ គឺនៅសល់ គេសំពាយពេលដែលសល់នោះទៅជាពេលដែលនៅបន្ទាប់ឆ្វេងដៃរួចគេបូក ទើបឃើញលទ្ធផលប៉ុន្មានយកទៅចែកនឹងចំនួនដុំនោះតាមលំដាប់តៗទៅ ។

វិធីហាត់មាត់ទទេ.— អ្នកជិះទោចក្រយាន ១ ជិះបានគន៍មួយម៉ោង ១២ គីឡូម៉ែត្រ តើចម្ងាយ ៣៦ គ.ម គេជិះប៉ុន្មាន ម៉ោង? ។ល។

វិធីហាត់សរសេរ.— កប៉ាល់សមុទ្រមួយបើកបានចម្ងាយ ២៤០០ គ.ម.គន៍ ៨៥ ម៉ោង តើគន៍ ១០០ គម កប៉ាល់នោះបើកប៉ុន្មានម៉ោង? ។ល។

មេរៀនទី ២.— លេខចែកនឹង ០,៥០ — ០,២៥ ដើម្បីនឹងចែកចំនួនគូនឹង០,៥ គេត្រូវគុណចំនួននោះនឹង ២ ឧបមាៈ ទំមួយថ្លៃ ០ៗ ៥០ តើប្រាក់ ៧ៗ, ទិញបានទំប៉ុន្មាន? គឺៈ យក ៧ៗ គុណនឹង ២ ឃើញបានទំ

១៤  ដើម្បីនឹងចែកចំនួនអ្វីនឹង ០,២៥  គេត្រូវគុណចំនួននោះនឹង ៤

ឧបមា: ស្លាបប៉ាកកាមួយថ្លៃ ០៛,២៥ តើប្រាក់ ៨៛, ទិញបានស្លាបប៉ាកកាប៉ុន្មាន ?

គឺ: យក ៧ គុណនឹង៤ ឃើញស្លាបប៉ាកកា ២៨ ។

វិធីហាត់គិតមាត់ទទេ.–

ចែកនឹង ០,៥០,: ប្រាក់ ៣៛ ; ៧៛ ; ១២៛ . ៨៛.៥០ ; ១៤៛,៥០ ទិញបានបន្ទាត់ប៉ុន្មាន បើបន្ទាត់មួយថ្លៃ ០៛,៥០ ។

ចែកនឹង ០,២៥: ដបទឹកខ្មៅមួយចំណុះ ០ល,២៥ តើបានទឹកខ្មៅប៉ុន្មានដបបើគេយក០ ទៅចាក់ ៧ល ; ៣ល,៥ ; ៤ល,២៥ ; ២៥ល ?

## រង្វាស់រង្វាល់

សូមសាបស្រៀនតាំងពីដើមឆ្នាំមកវិញ ហើយសាកសួរវិធីមុនៗ នឹងដាក់ចំណោទឲ្យសិស្សធ្វើឲ្យបានច្រើន ។

# អាទិកម្មន

## សត្ត ១

ទី ១.– សាបម្រៀនអំពីលេខបូកទាំងពីរយ៉ាងឡើងវិញ ។

វិធីហាត់មាត់ទទេ.– លេខបូកជាអ្វី ? ( ជាវិធីមួយសំរាប់ប្រមូលចំនួនអ្វីដែលដូចគ្នាមកធ្វើជាចំនួនមួយ ) ។ ដើម្បីនឹងសរសេរហើយនឹងបូកលេខនោះគេត្រូវសំគាល់ដូចម្តេច ? គេត្រូវសំគាល់ខ្ទង់ គឺចំនួនរាយក្រោមចំនួនរាយ ចំនួនដប់ក្រោមចំនួនដប់ ។ល។

វិធីហាត់សរសេរ.– ចូរធ្វើលេខបូកដូចមានដាក់នៅខាងក្រោមនេះ ៖

៦៦១៣រ,+២៣រុ+៥៣៖រុ= . . . . . ២២៧ម+៧៩២ម៥= . . . . .

២៥៦រ,៧+៥៨រ,៥៦+៩៦៣រ,៥= . . . . . ២៩៩ម៧២+៩៦២ម=។

៣. បំណោទ.– ទូកប៉ុកចាយមួយផ្ទុកឥដ្ឋបីថ្ងៃក្នុងថ្ងៃទី ១ ផ្ទុកបាន ៦៨៥ ដុំ ថ្ងៃទី ២ បាន ៤៦៩ ដុំ ថ្ងៃទី ៣ បានស្មើនឹងថ្ងៃទី ១ នឹងទី ២ រួមគ្នា តើក្នុង ៣ ថ្ងៃទូកនោះផ្ទុកបានឥដ្ឋប៉ុន្មានដុំ ? ។

៤- អ្នកស្រែម្នាក់បានទិញស្រូវ ២៧ហ ថ្លៃ ១៩៨៨៛,៧៥ រួច ៣៧ហ.៤៥០ ថ្លៃ ២.៤៧៥៛,៥០ ។ តើអ្នកស្រែនោះទិញទាំងអស់បានប៉ុន្មានហិកតូលីត្រ ? ហើយត្រូវលក់ស្រូវនោះទៅវិញថ្លៃប៉ុន្មានឲ្យបានចំណេញ ១២៩០៛,៧៥ ? ។

ទី ២.– សាច់រៀនអំពីលេខសងទៀតវិញ ។

១- វិធីហាត់មាត់ទទេ.– លេខសងជាអ្វី? (ជាវិធីមួយសំរាប់ដកប្តូកាត់ចំនួនតូចមួយពីចំនួនធំមួយ) ។ គេធ្វើលេខសងដូចម្តេច? (គេសរសេរចំនួនតូចដាក់ក្រោមចំនួនធំឲ្យត្រង់ជួរ គឺខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់ដប់ក្រោមខ្ទង់ដប់) ។ល។

២- វិធីហាត់សរសេរ.– ចូរធ្វើលេខសងខាងក្រោមនេះបាន ធ្វើបញ្ជាក់ឲ្យដឹងខុសត្រូវផង ។

២៨៧៧ម–៤៣៩ម= .....។ ១៥៣២ម-៧៥៣ម៤៥.....។

៩៩២៛,៨–៥៣៦៛,.......។ ៧៩២៣៛,៦៥–២៨៤៛,៧៨...។

៣- បំណោទ.– ជាងឈើម្នាក់មានប្រាក់ ២២៥៣៩៛,៥០ ហើយគេទិញឈើមួយកន្លែងអស់ ៧៦៦៤៛,២៥ មួយកន្លែងទៀតអស់ ៨២៨៦៛,៦០ តើជាងឈើនោះនៅសល់ប្រាក់ប៉ុន្មានទៀត ? ។

៤· ដស្ទើ ម្នាក់ចេញថ្លៃឲ្យកូនជាង ៣ នាក់ចំនួនប្រាក់ ៧០០៛, ។ កូនជាងទីមួយបាន ២៥៧៛,៧៥ ជាងទី ២ បានតិចជាងទី១ មួយ ៣៩៛,៥០ ហើយជាងទី ៣ ត្រូវបានប្រាក់ដែលនៅសល់ តើម្នាក់ៗត្រូវបានប៉ុន្មាន? ។

ទី ៣.– សាបស្រៀនអំពីលេខគុណចំនួនដុំនឹងចំនួនទសភាគ លេខគុណនឹង ១០ ។ ១០០ ។ ១០០០ ។ ហើយនឹងរបៀបធ្វើបញ្ចាក់ឲ្យ-ឃើញខុសត្រូវនោះឡើងវិញផង ។

វិធីហាត់មាត់ទទេ.– លេខគុណជាអ្វី ? (ជាវិធីមួយសំរាប់បង្កើនចំនួនមួយឲ្យចំរើនធំឡើងមានកំណត់) ។ លេខតំណាំងគឺអ្វី ? មេគុណគឺអ្វី ?

មួកមួយថ្លៃ ៥៛ បើមួក ៥ ។ ១០ ។ ១០០ ។ ១០០០ ។ ថ្លៃប៉ុន្មាន? ។ គេធ្វើដូចម្តេចដើម្បីនឹងគុណចំនួនគត់នឹង ១០ ។ ១០០ ។ ១០០០ ។ បើលេខតំណាំងជាចំនួនមានបែងភាគកុយគេធ្វើដូចម្តេច? ។ល។

២.– បំណោទ.– ចិនម្នាក់ទិញមួក ៥២ ហើយលក់ទៅវិញថ្លៃ ១៨០៛មួយ ប្រចិននោះគិតឃើញបំណេញទាំងអស់ ៦៣០៛ តើថ្លៃដើមមួកនោះទាំងអស់ប៉ុន្មាន ? ។

៣.– ជាងឈើម្នាក់រកបានកូនមួយថ្ងៃ ១៦៛៥០ វាធ្វើការរាល់ថ្ងៃក្នុង ១ ឆ្នាំ លើកតែ ៥២ ថ្ងៃអាទិត្យ ហើយនឹងថ្ងៃបុណ្យ ៦ ថ្ងៃចេញ ។ ថ្ងៃឈ្នួលផ្ទះ ៧២០៛ ហើយសន្សំទុកបាន ៦០០៛ តើជាងនោះនៅសល់ប្រាក់ប៉ុន្មានទុកនឹងចាយវាយក្នុងគ្រួសារ? ។

ទី៤.– សាបង្រៀនអំពីលេខចែក ដែលបានបង្រៀនក្នុងឆ្នាំនេះឡើងវិញ ។

១– វិធីហាត់មាត់ទទេ.– សូមមើលវិធីនេះក្នុងកិច្ចសិក្សាបឋមវិជ្ជា តាំងពីខែសេបតមប្រ៍ រហូតមកដល់ខែម៉ែនេះ ។

២ – ចំណោទ.– ឈ្មួញម្នាក់ទិញសំពត់ហូល ៨ ហើយលក់ទៅវិញទាំងអស់បានប្រាក់ ៦៤០រៀល គេគិតទៅឃើញបានចំណេញ ១៥០ រៀល តើថ្លៃដើមសំពត់នោះ ១ ប៉ុន្មាន? ។

## រង្វាស់រង្វាល់

ទី ១. សាបង្រៀនអំពីរង្វាស់ប្រវែងឡើងវិញ ។

១. វិធីហាត់មាត់ទទេ.– ខ្នាតដើមនៃវិធីវាស់ប្រវែងនោះគឺអ្វី ? ម៉ែត្រ

គេធ្វើអំពីអ្វី ? មានបែបយ៉ាងណាខ្លះ ? រង្វាស់តូចជាងម៉ែត្រនោះគឺអ្វីខ្លះ ? ខ្នាតធំជាងម៉ែត្រនោះគឺអ្វីខ្លះ ?

**វិធីហាត់សរសេរ** – ឲ្យសរសេរជាម៉ែត្រចំនួនខាងក្រោយនេះ ៖

១៧ម ។ ៨ ហ.ម ។ ៣២ ដ.ក.ម ។ ២៥ ស.ម ។ ៧ ហ.ម ។ ៨០០០ ម.ម ។ ៨៥៣ ស.ម ។ ៤ ដ.ម ២៥ ស.ម ។

**បំណោទ**.– អ្នកវេញខ្សែម្នាក់ វេញខ្សែនៅថ្ងៃចន្ទបាន ៣៥ ម៉ែត្រ ថ្ងៃអង្គារបាន ៨ ម៉ែត្រ លើសថ្ងៃចន្ទ ហើយថ្ងៃពុធបាន ៩ ម៉ែត្រ លើសថ្ងៃអង្គារទៀត ។ តើក្នុង ៣ ថ្ងៃនោះ គេវេញខ្សែបានប៉ុន្មានម៉ែត្រ?

៣. ឈ្មួញម្នាក់ជំពាក់ទំនិញគេ ៩៦៦៛៥០ វាសងជាប្រាក់ ១២៥៛៥០ ហើយនៅសល់ប៉ុន្មានឲ្យជាសំពត់គិតថ្លៃ ១៤៛, ក្នុង ១ ម៉ែត្រ ។ តើឈ្មួញនោះត្រូវសងសំពត់ទៅគេប៉ុន្មានម៉ែត្រ? ។

ទី ២.– សាបស្រៀនអំពីរង្វាល់ចំណុះ

**វិធីហាត់មាត់ទទេ**.– ចោទសួរពីតារណា អំពីរាល់ នឹងផ្លាស់រង្វាល់ធំទៅតូច រួចតូចមកធំវិញ ។

២. **បំណោទ**.– គេចាក់ទឹកទៅក្នុងថាំងធំមួយ ។ លើកដំបូង ២ ហ.លិ គន្ទុះ មួយលើកបន្ទាប់ ៤ ដ.ក.លិ គន្ទុះ ហើយលើកក្រោយបំ–

ផុត ២៤ លីត្រ គេសួរថាចុះគេចាក់ទឹកទៅក្នុងថាំងនោះទាំងអស់ប៉ុន្មាន? ។

ទី ៣ និង ៤.— ១. សាបគ្រៀនអំពីរង្វាល់ចំណុះដែលមានរូបជាក់ស្ដែងគឺ រង្វាល់ដែលមានធ្វើទុកកាន់វាល់ផ្ទាល់នឹងដៃបាន ។

២. សាបគ្រៀនអំពីរូបិយវត្ថុ ដែលបានបង្រៀនរួចមកហើយ ។

បំណោទ.— ១. ចិនម្នាក់ទិញស្រា ១៥ ឌុទិន ថ្លៃមួយឌុទិន ៦២៛៥០ ហើយចិននោះលក់ពាយទៅវិញ ១០៛៣០ ក្នុង ១ លីត្រ តើចិននោះចំណេញបានប៉ុន្មាន បើក្នុង ១ ឌុទិនមានចំណុះ ២.ដ.ក.លក្ខុះ?។

២. មានបងប្អូន ៣ នាក់នៅស៊ីឈ្នួលឲ្យគេក្នុង ១ ខែ បងបង្អស់បានឈ្នួល ៨៛៥០ ប្អូនបន្ទាប់បាន ៦៛៤០ ប្អូនពៅបាន ៤៛៧០ គេសួរថាចុះទាំងអស់គ្នាបានសល់ប្រាក់ប៉ុន្មានរៀលមកផ្ទះ បើក្នុងគំឡុងធ្វើការនោះ ១អាទិត្យហើយវាចាយទាំងអស់គ្នាអស់ ៧០ រៀល? ។

## មធ្យមដ្ឋានទី ១ និង អាទិកដ្ឋាន

### ធរណីមាណសាស្ត្រ

ក្នុងខែនេះសូមលោកគ្រូរើសយកមេរៀនណាដ៏សំខាន់ៗ ដែលបានបង្រៀនក្នុងឆ្នាំសិក្សាមកបង្រៀនឡើងវិញ ។

អាទិកង្ហន

## វិត្តស្វាធ្យាយន៍

ក្នុងថ្ងៃនេះសូមលោកគ្រូបង្រៀនសារដើមឡើងវិញ ។

# បរិច្ឆណាង្គន

## ឥព្វន្ត

មេរៀនទី ១.- សាបញ្ជាក់អំពីលេខបូកចំនួនដុំនិងចំនួនបែងភាគដែលបានរៀនរួចមកហើយ ។

របៀបបង្រៀន.- ចោទជាចំណោទបែបដូចជា៖

ម្តាយខ្ញុំលក់អង្ករ១តៅបានប្រាក់២៨៛, លក់មាន់២បានប្រាក់៣៤៛, លក់កូនជ្រូក១បានប្រាក់៧៣៛, ។ តើគាត់ត្រូវបានប្រាក់ទាំងអស់ប៉ុន្មាន ? ។

របៀបពន្យល់ដោយចោទសួរ.- ក្នុងចំណោទនេះគេសួររកអ្វី ? គេត្រូវធ្វើដូចម្តេច ? ចូរធ្វើលេខបូកនោះទៅមើល ?

កាលណាសិស្សធ្វើលេខបូកនោះត្រឹមត្រូវហើយ ត្រូវតាងចំណោទ ១ទៀតដែលមានលេខបូកចំនួនទសភាគ ។ បើសិស្សចេះសព្វគ្រប់ ហើយត្រូវដាក់ការហាត់សរសេរឲ្យធ្វើនៅក្នុងសៀវភៅ បើពិនិត្យទៅឃើញថាសិស្សពុំទាន់យល់ច្បាស់ត្រង់កន្លែងណា ត្រូវសាពន្យល់កន្លែងនោះឲ្យសិស្សយល់ច្បាស់ឡើង ។

ការហាត់សរសេរនៅក្នុងសៀវភៅ .– ចំណោទ

១ – ស្រីម្នាក់ទៅផ្សារទិញអង្ករ ៤ តៅអស់ប្រាក់ ៦៣រៀល ទិញសំពត់ ៥ម អស់ប្រាក់ ១០៧ រៀល ហើយនឹងទិញម្ហូបអាហារអស់ ២៥ រៀល ។ តើស្រីនោះចាយប្រាក់ទាំងអស់ប៉ុន្មាន ? ។

២ – អ្នកចំការម្នាក់ទៅផ្សារលក់ផ្លែឈើបានប្រាក់ ២៣$^{r}$,៥៣ លក់បន្លែបានប្រាក់ ១៧$^{r}$,៤៦ ។ តើអ្នកនោះលក់បានប្រាក់ទាំងអស់ប៉ុន្មាន ?។

មេរៀនទី ២ .– សាបញ្ជាក់អំពីលេខសងចំនួនដុំនឹងចំនួនទសភាគដែលបានរៀនរួចហើយ ។

សូមមើលតាមរបៀបខាងនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី ៣ .– សាបញ្ជាក់អំពីលេខគុណចំនួនដុំនឹងចំនួនទសភាគ មេគុណមានលេខតែមួយតួ ។

មេរៀនទី ៤ សាបញ្ញាក់អំពីលេខចែកចំនួនធំ – ចំនួនទសភាគនឹងលេខហាមានលេខតែមួយតួ ។

សូមតែងការហាត់ឲ្យសព្វគ្រប់តាមរបៀបខាងលើនេះផង ។

## រង្វាស់រង្វាល់

មេរៀនទី ១ .– សាបញ្ញាក់អំពីរង្វាស់ (ម៉ែត្រ)

រង្វាស់ដែលធំជាម៉ែត្រ – តូចជាងម៉ែត្រ នឹងរង្វាស់ដែលមានជាប្រធាន ។

មេរៀនទី ២ .– សាបញ្ញាក់អំពីរង្វាល់ (លីត្រ)

រង្វាល់ដែលធំជាងនឹងតូចជាងលីត្រ រង្វាល់ដែលមានជាប្រធាន ។

មេរៀនទី ៣ .– សាបញ្ញាក់អំពីកូនទម្ងន់ (ក្រាម)

កូនទម្ងន់ធំជាងនឹងតូចជាងក្រាម កូនទម្ងន់ដែលមានជាប្រធាន ។

មេរៀនទី ៤ .– សាបញ្ញាក់អំពីប្រាក់ដែលចាយ

នៅប្រទេសឥណ្ឌូចិន ។

ការចំណាំ .– សូមបង្វឹកសិស្សឲ្យចេះវាស់ – វាល់ – ថ្លឹង – ដូរ

ប្រាក់ – ថែមថយប្រាក់ឲ្យបានស្ទាត់ផង ហើយសូមតែងការហាត់ឲ្យបានសព្វគ្រប់ផង ។

---

# កុមារដ្ឋាន

## នព្វន្ត

តាមកំណត់ចែកវិជ្ជាក្នុងខែនេះជាខែចុងឆ្នាំសិក្សា សូមសាបង្រៀនមេរៀនផ្សេងៗ ដែលបានរៀនតាំងពីដើមឆ្នាំមក ឲ្យសិស្សធ្វើចំណោទផ្សេងៗ នឹងហាត់ធ្វើលេខ ។

## រង្វាស់រង្វាល់

សូមសាបង្រៀនមេរៀនផ្សេងៗ ដែលបានរៀនតាំងពីដើមឆ្នាំមក ឲ្យសិស្សហាត់គិតធ្វើលេខ នឹងធ្វើចំណោទផ្សេងៗឲ្យបានច្រើន ។

# មជ្ឈិមដ្ឋាន ទី ២

## មេរៀនជាគំរូ

វិទ្យាសាស្ត្រ .– អំពីលុយមួយសេន(ទង់ដែង).

ប្រដាប់សំរាប់បង្រៀន .– សុំលោកគ្រូឬសិស្សរកលុយសេន ទង់ដែង - សេនសំណ - ទឹកម្ជូរ - កំណាត់សំពត់ - ជញ្ជីង - កូនទម្ងន់ ។ល។ យកមកនាំសិស្សពិនិត្យមើល : រូបរាង - ចម្លាក់ខាងមុខ - ខាង-ក្រោយឬខ្នងលុយ លុយសេននោះ ហើយឲ្យរៀនស្ទាបទម្ងន់លុយទាំង-នោះផង - រួចបញ្ជាក់ទម្ងន់សេននិមួយនឹងជញ្ជីង ។ល។....

ការនាំសិស្សពិនិត្យមើល .– លុយសេននេះរាងដូចម្តេច? (មូល) វាមូលដូចអ្វី? (មូលសំប៉ែតដូចជាកាស់) ។ លុយសេននេះមាន ពីរចំណែក ហើយហាមជុំវិញ ។ ចំណែកទី១ហៅថាខាងមុខ ។ នៅខាង មុខលុយសេននេះឃើញអ្វីខ្លះ? (ឃើងឃើញរូបស្ត្រីពីរនាក់ ម្នាក់អង្គុយ នៅខាងលើរន្ទ ម្នាក់ទៀតនៅខាងក្រោមហើយខាងស្តាំរន្ទ ។ ស្ត្រីនេះ កាន់អ្វីនៅដៃខាងស្តាំ? (កាន់ទង់ជាតិ) ។ ស្ត្រីម្នាក់ទៀតអង្គុយដូចម្តេច?

(អង្គុយសន្ធឹងដៃកាន់សំពត់បាំងឲ្យស្រីនេះ) ។ នៅលើក្បាលមានពាក់អ្វី? (មានពាក់មួកបារាំងហៅថា (Bonnet) នៅខាងក្រោមរូបយើងឃើញអ្វី? (ឃើញលេខ ១ និងពាក្យថា «Cent» គឺថ្លៃសេននេះ (១សេន) ។ អក្សរនៅព័ទ្ធជុំវិញរង្វង់សេននេះជាដូចម្ដេច? (République française) យើងកាត់វាស់ទទឹងសេនចំពាក់កណ្ដាល - វាមានប្រវែង២៦មីលីម៉ែត្រ ។ មានកម្រាស់ប្រហែលពីរមីលីម៉ែត្រ ។

យើងត្រឡប់សេននេះ មើលពីខាងខ្នងទៀត ។ យើងឃើញមានអ្វីនៅជុំវិញរន្ធកណ្ដាល? ឃើញអក្សរចិន្ដបួនតួ នៅក្បែរហោម មានគន្លួលដូចជាពងត្រីព័ទ្ធជុំវិញ ។ យើងឃើញមានពាក្យអ្វីទៀត ។ (មានពាក្យថាឥណ្ឌូចិនបារាំងសែស – Indochine française) នៅកន្ទុងនេះយើងឃើញមានអ្វី? (ឃើញលេខ ១៩២១) ។ លេខនេះគេដាក់សំគាល់អ្វី? (សំគាល់ឆ្នាំដែលបោះពុម្ពលុយសេននេះ ។ សេននេះមានពណ៌ដូចម្ដេច? (ក្រហម) យើងដុសលាងសេននេះនឹងទឹកម្ជូរ តើវាមានពណ៌យ៉ាងណាវិញ? (ពណ៌លឿងចាស់ហើយភ្លឺ) ។ មានលោហធាតុណាខ្លះដែលមិនបាច់ដុសខាត់ហើយភ្លឺដូចជាសេននេះ? (មាសទង់ហ្វ៊ា ។

— យើងទម្លាក់សេននេះទៅលើឥដ្ឋ វាឮសូរដូចជាកណ្ដឹង ដូច្នេះសេននេះមិនមែនធ្វើពីដែកសុទ្ធទេ ។ គឺជាលោហធាតុលាយ ហៅថាទង់ដែង ។

គេលាយលោហធាតុអ្វីខ្លះ? ទើបបានជាទង់ដែងនេះ? ( ស្ពាន់ ៣ ភាគសំណប៉ាហាំង ១ ភាគ ) ។

ស្មានទម្ងន់លុយសេន .– សេននេះធ្ងន់ប្រមាណ? -- ប្រហែលប៉ុន្មានក្រាម? សុំឲ្យសិស្សស្មានទម្ងន់ឲ្យបានច្រើនគ្នា ហើយកត់ចំនួនទម្ងន់ដែលសិស្សស្មានទាំងនេះទៅលើក្ដារខៀនបញ្ជីរ រួចថ្លឹងបញ្ជាក់ទម្ងន់សេននេះនឹងជញ្ជីង ឲ្យសិស្សឃើញទៀតផង ។

ប្រយោជន៍នៃទង់ដែង .– គេមិនគ្រាន់តែយកទង់ដែងមកធ្វើលុយសេនសំរាប់ចាយនេះទេ គេយកទៅធ្វើការជាច្រើនយ៉ាងគឺធ្វើគ្រឿងយន្តផ្សេង ៗ ពីព្រោះទង់ដែងស្វិតជាងលោហធាតុឯទៀត ។ល។

មេរៀនសង្ខេប .– សូមលោកតែងមេរៀនសង្ខេបនឹងពាក្យងាយៗ

## មេរៀនក្នុងខែ

១ – អំពីលោហធាតុ ៖ ដែក – ស្ពាន់ ។ ២ ការលាយលោហធាតុ ។

៣ – សារបង្រៀនមេរៀនខែមុន ៗ ឡើងវិញ ។

## អនាម័យ

សូមសារបង្រៀនពីដើមឡើងវិញ ។ គឺបង្រៀនតែមេរៀនណាដែលមានប្រយោជន៍ជាងគេ ។

# ឧត្តមដ្ឋាន

## មេរៀនជាគំរូ

**វិទ្យាសាស្ត្រ.-** *អំពីធ្យូងថ្ម - ប្រេងកាត*

**ប្រដាប់សំរាប់បង្រៀន.-** *ធ្យូងឈើ- ធ្យូងថ្ម- ប្រេងកាត ជើងក្រានធ្យូង ៗ ល ៗ យកមកដុតបង្កាត់ក្នុងជើងក្រានឲ្យសិស្សពិនិត្យមើល ហើយចោទសួរសិស្សតាមរឿងដូចមានតទៅ ៗ*

**ការនាំសិស្សពិនិត្យមើល.--** *យើងធ្លាប់បានឃើញធ្យូងឈើជាញឹកញយណាស់ ពីព្រោះទីក្រុងធំ ៗ នៅផែនកម្ពុជរដ្ឋយើងនេះគេច្រើនប្រើធ្យូងឈើដុតចំអិនអាហារ ជាជំនួសឧស ឯធ្យូងថ្មនៅស្រុកយើងគ្មានទេ ធ្យូងថ្មនេះនៅក្នុងដី គេហៅថាធ្យូងដីក៏បានដែរ វានៅក្នុងដីជាផ្ទាំងស្តើង ៗ ដូច្នេះកាលណាគេយកធ្យូងថ្ម គេជីកអណ្តូងឲ្យមនុស្សចុះទៅកាប់ឬដាប់យក ៗ ជួនកាលធ្យូងថ្មនេះមាននៅក្នុងដីរាក់ ៗ គេគ្រាន់តែជីកបន្តិចទៅក៏យកបានហើយ ៗ.*

ប្រដាប់ប្រដាអ្នកចុះទៅយក ធ្យូងថ្មមានបបនឹងញញួរជាដើម គេបំ-ភ្លឺក្នុងអណ្ដូងយកធ្យូងថ្មនេះនឹងចង្កៀងមួយយ៉ាង ដែលមានអំណាចរំងាប់ខ្យល់មិនល្អចេញផ្សាយពីធ្យូងថ្មមក ។

នៅដែនតុងកឹងមាន កន្លែងយកធ្យូងថ្មជាច្រើនកន្លែងធំជាងគេនៅប្រ-ទេសនោះ គឺនៅហុងកៃក្នុងខេត្តក្វាងយ៉េន ធ្យូងថ្មដែលគេយកនៅកន្លែងនោះមាននៅសើលើដី ។

ធ្យូងថ្មប្រើការសំរាប់ដុតភ្លើងជើងក្រានកំដៅផ្ទះនៅស្រុកត្រជាក់ដូចជានគរបារាំងជាដើម ។ គេដុតដាំទឹកយកចំហាយប្រើការក្នុងម៉ាស៊ីនទាំងពួង ដូចជាម៉ាស៊ីនកប៉ាល់សមុទ្រ ម៉ាស៊ីនរទេះភ្លើង ។ល។

ឯប្រេងកាតគឺជាប្រេងចេញមកពីថ្ម មាននៅក្នុងដីជាអណ្ដូង ជួនកាលមានផុសចេញឡើងលើដីហូរទៅជ្រោះ ។ ប្រេងកាតសំរាប់ដុតយកពន្លឺ បំភ្លឺផ្ទះ ដុតភ្លើងម៉ាស៊ីនគ្រប់មុខ ។ល។

មេរៀនសង្ខេប –. ធ្យូងថ្មគឺជាធ្យូងនៅក្នុងដីជាផ្ទាំងស្តើង ៗ សំរាប់ដុតកំដៅក្នុងផ្ទះក្នុងវេលាដែលរងាខ្លាំង ហើយដុតដាំទឹកម៉ាស៊ីន ។ កាលណាគេយកធ្យូងថ្មគេជីកអណ្ដូង ប្រដាប់សំរាប់ធ្វើការក្នុងអណ្ដូង

នោះ គឺចប ញញួរជាដើម ហើយបំភ្លឺនឹងចង្កៀងមួយយ៉ាងដើម្បីនឹងរំងាប់ខ្យល់មិនល្អ ដែលចេញពីធ្យូងថ្មនោះមក ។

នៅប្រទេសតុងកឹងមានអណ្តូងយកធ្យូងថ្មជាច្រើនកន្លែងៗដែលសំខាន់ជាងគេគឺនៅហុងកៃ ក្នុងខេត្តក្វាងយ៉េន ។

ពាក្យសួរក្នុងមេរៀន ៖— ដូចម្តេចហៅថាធ្យូងថ្ម ? ធ្យូងថ្មសំរាប់ប្រើការធ្វើអ្វីខ្លះ ? បើនឹងយកធ្យូងថ្ម គេត្រូវធ្វើដូចម្តេច ? គេប្រើប្រដាប់អ្វីខ្លះ ? នៅប្រទេសកម្ពុជាមានកន្លែងយកធ្យូងថ្មឬទេ ? មាននៅប្រទេសណា ? ។ល។

---

## អនាម័យ

ការដែលត្រូវប្រយ័ត្នខ្លួន ឬ ចៀសវាង

កុំឲ្យកើតរោគនៅវេលាដែលជម្ងឺអហិវាតរោគឬជម្ងឺពិស ។

(សូមបង្រៀនតាមសៀវភៅវិធីបង្ការរោគពីទំព័រ ២៨ ទៅដល់ ២៩ មេរៀនទី១៨) ។

## មេរៀនក្នុងខែ

សូមសាបង្រៀនពីដើមឡើងវិញទាំងអស់ ។

---

# មជ្ឈិមដ្ឋានទី ១

## វិត្តស្វាធ្យាយន៍

អាទិត្យទី ១. – ប្រៃសណីយ - ទូរលេខ, ទូរសព្ទ មានខ្សែនិងទូរសព្ទឥតខ្សែ -

មេរៀនសង្ខេប. – គេផ្ញើដំណឹងកាន់គ្នាទៅវិញទៅមកដោយសំបុត្រឬដោយទូរលេខ ឬ ទូរសព្ទ ។

ដើម្បីនឹងផ្ញើសំបុត្រ គេត្រូវបិទតែមតាមកំណត់ច្បាប់ហើយយកសំបុត្រនោះទៅដាក់ក្នុងប្រអប់សំរាប់ទទួលសំបុត្រនៅឯមន្ទីរប្រៃសណីយ ។ នៅមន្ទីរនោះភ្នាក់ងារប្រៃសណីយចាត់ផ្ញើសំបុត្រនានាឲ្យអ្នកទទួលដល់ទីកន្លែងតាមអាស័យដ្ឋាន (ម. ថ. អាស័យ - យ៉ាត់ - ដ្ឋាន: adresse ដោយរថយន្ត, រថភ្លើង, យន្តហោះ ឬ ដោយកប៉ាល់ ។

(សុំគ្រូយកស្រោមសំបុត្រមួយមកបង្ហាញសិស្ស ហើយបង្ហាញរបៀបការខ្នងនឹងរបៀបបិទតែម)

ទូរលេខជាគ្រឿងមួយបែបសំរាប់ផ្ញើដំណឹងបានយ៉ាងឆាប់ទាន់ចិត្ត ។ គ្រឿងនេះដើរ ដោយ កម្លាំងអគ្គិសនីហើយភ្ជាប់ពីកន្លែងមួយទៅកន្លែង

មួយដោយខ្សែលួសធ្វើពីលោហធាតុ ។ ដូចណា គេបង្កប់ខ្សែលួសនេះតាមបាតសមុទ្រឬទន្លេក៏មាន ។ ក្នុងការប្រើគ្រឿងនេះ គេសន្មតប្រើគំនូសជំនួសព្យញ្ជនៈនានា ។

ឧទាហរណ៍ a:.—; b:—...; c:—.—. ។

ទូរសព្ទមានខ្សែ គឺជាគ្រឿងសំរាប់ផ្ញើសព្ទឬសញ្ញា ដែលគេសន្មតប្រើតាមលំហអាកាសដោយឥតចាំបាច់ប្រើខ្សែឡើយ ។

អាទិត្យទី ២.— ម៉ាស៊ីនដើរដោយកម្លាំងចំហាយទឹក-

ទឹកពុះក្នុងកំសៀវអាចធ្វើឲ្យគំរបកំសៀវរបើកបានមកពីកម្លាំងចំហាយទឹក ។ បើកាលណាគេយកបំពង់ដែកមួយមកដាក់ទឹកពាក់កណ្ដាល ហើយបុកឲ្យជិតរួចយកទៅកំដៅភ្លើងមិនយូរប៉ុន្មានទឹកនឹងពុះ បន្ទាប់មកគេនឹងឃើញឆ្នុកនោះខ្ទាតចេញជាពុំខានដោយសារចំហាយទឹកជាក់ ។

គឺកម្លាំងចំហាយនេះហើយដែលនាំឲ្យម៉ាស៊ីនរថភ្លើងម៉ាស៊ីនកិនស្រូវ បើកបរបាន ។ តែដើម្បីនឹងឲ្យទឹកពុះមានចំហាយ គេត្រូវដុតធ្យូងឲ្យមានកំដៅខ្លាំង ។ ដូច្នេះ សម្រេចទៅគឺភ្លើងធ្យូងទេ ដែលជាហេតុនាំឲ្យគ្រឿងម៉ាស៊ីនកប៉ាល់ឬរថភ្លើងដើរបាន ។

អាទិត្យទី ៣.— រថយន្តនឹងយន្តហោះ

ម៉ាស៊ីនចំពូកនេះមិនដើរដោយកំឡាំងចំហាយទឹកពុះឡើយ គេដឹង

ថា គ្រោះថ្នាក់នឹងមានជាប្រាកដដល់ជនណាដែលកាន់ចង្កៀងឬចន្លុះ ដែលកំពុងឆេះមានអណ្ដាតចូលទៅក្នុងកន្លែងណាមួយដែលមានចំហាយប្រេងសាំង ព្រោះចំហាយប្រេងសាំងនឹងខ្យល់លាយគ្នា តែកាលណាមកប៉ះអណ្ដាតភ្លើងនឹងឆេះហើយផ្ទុះផង ។

អ្នកប្រើចង្កៀងដុតស្រាចាស់ពេកឬខូចក៏មានគ្រោះថ្នាក់ដែរ ពីព្រោះចំហាយស្រាដុតលាយនឹងខ្យល់តែប៉ះនឹងអណ្ដាតភ្លើងក៏ឆេះហើយផ្ទុះដែរ ។

គឺកម្លាំងដែលប្រេងសាំងនឹងខ្យល់ឆេះផ្ទុះនេះហើយដែលជាហេតុនាំឲ្យម៉ាស៊ីនរថយន្តនឹងម៉ាស៊ីនយន្តហោះ ដើរបាន ។

អាទិត្យទី ៤ — រៀនសាឡើងវិញ ·

## វិធីបង្ការរោគ

## កាយសិក្សា

១ — កិរិយាបថ — យើងបានដឹងថាឆ្អឹងកូនក្មេងទន់អាចផ្លាស់រាងបានដោយងាយ ៗ ដូច្នេះយើងពុំត្រូវបង្ខំឲ្យក្មេងឆាប់រៀនដើរឡើយ ៖ ឆ្អឹងជើងវានឹងកោងជាប់រហូតដោយទម្ងន់ខ្លួនសង្កត់ ។

ចូរអ្នកទប់ដំហារឲ្យត្រង់ទោះជាអ្នកអង្គុយឬឈរក៏ដោយ ។ ឆ្អឹងខ្នងក៏ទន់ណាស់ដែរហើយអាចក្លាយកងបានដោយងាយ ។

ឥរិយាបថមិនល្អបណ្ដាលមិនឲ្យទ្រូងរីកបានដោយលំដាប់តាមទម្លាប់ធម្មជាតិនឹងនាំឲ្យការដកដង្ហើម ពុំបានស្រួលដែលជាហេតុនាំឲ្យយើងកើតរោគបានដោយងាយ ។

២ - កាយសិក្សា - ដើម្បីឲ្យមានរាងសមល្អ មានខ្លួនមាំខ្លាំងធ្វើអ្វីបានដោយងាយអ្នកត្រូវធ្វើសាច់ដុំឲ្យរីកធំឡើង គឺត្រូវឲ្យសាច់ដុំនេះធ្វើការ ។ មុខនឹងកាយសិក្សាដែលសំខាន់ហើយងាយជាងគេគឺការដើរទៅកន្លែងណាដែលមានខ្យល់អាកាសល្អ ។

ល្បែងគ្រប់យ៉ាងនិងកីឡា ( ទាត់បាល់ , ហែលទឹក , វាយកូនឃ្លី ) ក៏វិសេសដែរ តែចូរអ្នកកុំប្រព្រឹត្តល្បែងទាំងនោះឲ្យហួសកំឡាំង ។ ការហត្ថកម្ម ( ជាងឈើ ) ការប្បារដំណាំ ) នាំឲ្យសុខកាយដែរ ។

ចូរអ្នកបំពេញកាយសិក្សាឲ្យបានតាមរបៀបក្បួនខ្នាតក្នុងមួយថ្ងៃឲ្យបានកន្លះម៉ោង ។

កាយសិក្សានាំឲ្យអ្នកបំភ្លេចការហត់នឿយខាងបញ្ញា នាំឲ្យអ្នកឆ្ងាញ់បាយឲ្យការដកដង្ហើមនឹងការឈាមរត់ដើរតែបានស្រួលល្អ ។

៣– ការសម្រាក – តែបើអ្នកប្រកាន់ល្បែង កីឡាឬការហាត់ប្រាណច្រើនហួសពេក សាច់ដុំអ្នកមិនមែនលូតលាស់ទេត្រឡប់ជាសឹកទៅវិញ ។ ដូច្នេះចូរអ្នកសំរាកនៅពេលក្រោយអ្នកហាត់រួច ។ ការសម្រាកសំខាន់ជាងគេបំផុតគឺដំណេកនៅពេលយប់ ។ ចូរអ្នកធ្លាប់អាស្រ័យដំណេកហើយធ្លាប់ភ្ញាក់ ។ ក្មេងត្រូវអាស្រ័យដំណេកក្នុងមួយថ្ងៃ ១០ ម៉ោង – ជំទង់ ៩ ម៉ោង, កម្លោះ ៨ ម៉ោង ។

---

## មជ្ឈិមដ្ឋានទី ២ នឹងឧត្តមដ្ឋាន

## លោកនីតិ

### មេរៀនទី ១.– អំពីរដ្ឋសភា

រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។ រដ្ឋសភាមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ។ ច្បាប់ជាសេចក្ដីសំដែងឆន្ទៈរបស់ប្រជាជាតិ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ បើ

ទោះជាច្បាប់នោះត្រាការពារក្តី ផ្តន្ទាទោសក្តី បង្ខិតបង្ខំក្តី ។ គណៈរដ្ឋ-មន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះរាជអាណាចក្រ ។

អ្នកដែលមានសិទ្ធិផ្តើម គំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភានិងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអា-ណាចក្រ ។ ច្បាប់ដែលសមាជិកនៃរដ្ឋសភាផ្តើមគំនិតតែងហៅថាសេច-ក្តីព្រាងបញ្ញត្តិ ។ ច្បាប់ដែលគណៈរដ្ឋមន្ត្រីផ្តើមគំនិតតែងហៅថា សេច-ក្តីស្នើបញ្ញត្តិ ។

សមាជិកទាំងឡាយ នៃរដ្ឋសភាជាអ្នកតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនត្រឹមតែជាអ្នកតំណាងរបស់ជនដែល ជ្រើសតាំងខ្លួនប៉ុណ្ណោះទេ ។ សមាជិកនៃរដ្ឋសភាមានចំនួន៨០រូប តាមច្បាប់ប្រកាសនៅគ.ស.១៩៤៧ ដែលស្តីអំពីការ ជ្រើសតាំងអ្នកតំណាងរាស្ត្រ ។ តាមគោលការណ៍ក្នុងចំនួនបុរសខ្មែរ ១០.០០០ នាក់ដែលមានអាយុ ២១-ឆ្នាំឡើងទៅត្រូវមានអ្នកតំណាងមួយរូប ។

អ្នកតំណាងរាស្ត្រត្រូវមានអាយុ ២៥ ឆ្នាំយ៉ាងតិច ហើយនៅក្នុងតំ-ណែងខ្លួនបានត្រឹមតែ ៤ ឆ្នាំទេ ។ មុននឹងចូលកាន់តំណែងសមាជិកនៃរដ្ឋសភាត្រូវតាំងសច្ចាប្រណិធានក្នុងទីប្រជុំចំពោះ ព្រះភក្ត្រព្រះមហា

ក្សត្រិយ៍ថាមានចិត្តស្មោះត្រង់ចំពោះព្រះភក្ត្រព្រះមហាក្សត្រិយ៍ថាមានចិត្តស្មោះ ត្រង់ចំពោះ ព្រះមហាក្សត្រិយ៍ ហើយនឹងរដ្ឋធម្មនុញ្ញ ។

អ្នកតំណាងរាស្ត្រមិនអាចត្រូវចោទប្រកាន់រកខ្លួនចាប់ខ្លួនឃុំឃាំងឬជំនុំជំរះក្នុងពេលដែលថិតក្នុងសមាជិកភាពទេ វៀរលែងតែអ្នកតំណាងរាស្ត្រនោះបានប្រព្រឹត្តបទល្មើស ដែលបានទាន់ឃើញជាក់ស្តែង ។

រដ្ឋសភាមានសម័យប្រជុំសាមញ្ញយ៉ាងតិច ពីរដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយ ៗ មានកំណត់យ៉ាងតិចបីខែ ។ ក្នុងសម័យប្រជុំសាមញ្ញពីរនេះ សម័យប្រជុំមួយត្រូវចាប់ផ្តើមក្នុងខែកញ្ញា ។

ព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់ហៅរដ្ឋសភាប្រជុំជាសម័យប្រជុំសាមញ្ញ ។

ក្រុមអភិបាលរដ្ឋសភាជាអ្នក ហៅសមាជិកប្រជុំជាសម័យប្រជុំវិសាមញ្ញ ដោយបានទទួលព្រះរាជបញ្ជាក្តី ដោយសេចក្តីណែនាំនៃគណៈរដ្ឋមន្ត្រីក្តីឬដោយសេចក្តីសុំ របស់ភាគមួយក្នុងភាគបី (១/៣) យ៉ាងតិចនៃចំនួនអ្នកតំណាងរាស្ត្រទាំងពួងក្តី ។

របៀបវារៈនៃសម័យប្រជុំវិសាមញ្ញនេះត្រូវផ្សាយដល់មហាជនព្រមជាមួយនឹងថ្ងៃណាត់ប្រជុំ ។ សេចក្តីកត់ហេតុនៃសម័យប្រជុំនោះត្រូវចុះផ្សាយក្នុងរាជកិច្ចផង ។

# មេរៀនទី ២ .- អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រនឹងរដ្ឋសភារួមគ្នាហៅថាសភា ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រគ្មានសិទ្ធិបញ្ចេញមតិតាំងច្បាប់ទេ ហើយកាន់អំណាចតិចជាងរដ្ឋសភាផង ។ គណៈរដ្ឋមន្ត្រីមិនទទួលខុសត្រូវចំពោះក្រុមប្រឹក្សាព្រះរាជអាណាចក្រទេ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រមានសមាជិកចំនួន២៤រូប ។ សមាជិកខ្លះត្រូវចាត់តាំង ខ្លះត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល ។ សមាជិកទាំងនោះត្រូវមានអាយុ ៤០ ឆ្នាំយ៉ាងតិច ។ អាណត្តិនៃទីប្រឹក្សាព្រះរាជអាណាចក្រមានកំណត់បួនឆ្នាំហើយទីប្រឹក្សាព្រះរាជអាណាចក្រ ត្រូវហៅប្រជុំហើយត្រូវប្រជុំក្នុងពេលជាមួយគ្នានឹងរដ្ឋសភា ។ ក្នុងមួយឆ្នាំៗ ក្រុមប្រឹក្សាព្រះរាជអាណាចក្រជ្រើសតាំងប៉ុយរូនឹងគណៈកម្មការនានារបស់ខ្លួនដូចរដ្ឋសភាដែរ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យហើយឲ្យយោបល់អំពីសេចក្តីព្រាងនឹងសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយ ព្រមទាំងអំពីបញ្ហាទាំងពួងដែលរដ្ឋាភិបាលបានដាក់ឲ្យពិនិត្យ ។

អំពីសេចក្ដីព្រាងនិងសេចក្ដីស្នើច្បាប់ ហើយនិងអំពីច្បាប់ថវិកា ក្រុមប្រឹក្សាព្រះរាជអាណាចក្រត្រូវឲ្យយោបល់កំណត់មួយខែយ៉ាងយូរ ។ បើជាការប្រញាប់កំណត់វេលានោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របានឲ្យយោបល់យល់ព្រម ឬពុំបានឲ្យយោបល់សោះ ក្នុងវេលាដែលមានកំណត់ទុកហើយនោះច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមហើយនោះ ត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។ បើជាការប្រញាប់ កំណត់វេលានោះត្រូវបន្ថយមកនៅត្រឹមតែពីរថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ សូមឲ្យកែសម្រួលសេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់ នោះរដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របដិសេធសេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់នោះ រដ្ឋសភាមិនអាចយកមកពិចារណាជាលើកទី ២ មុនកំណត់ពេលមួយខែទេ ។

ការពិនិត្យសេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់ជាលើកទីពីរនេះរដ្ឋសភាត្រូវបញ្ចេញមតិ ដោយវិធីបោះឆ្នោតចំហ យកតាមភាគច្រើនដោយដាច់ខាតនៃសមាជិករដ្ឋសភា ។ សេចក្ដីព្រាងឬសេចក្ដីស្នើច្បាប់ណាដែល

បានធ្វើសម្រេចដូចខាងលើនេះហើយ ត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។

## អំពីរបៀបជ្រើសតាំងតំណាងរាស្ត្រ

ក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ បណ្ដាជនទាំងអស់ជួយចាត់ចែងការគ្រប់ប្រទេសខ្លួន ប៉ុន្តែមិនមែនចាត់ចែងដោយចំពោះទេ គឺតាមរយៈនៃអ្នកតំណាងខ្លួន ៗ

ក្នុងសម័យបោះឆ្នោតមានបេក្ខជនជាច្រើន ឈរឈ្មោះឲ្យគេជ្រើសតាំងជាអ្នកតំណាងរាស្ត្រ ។ បុរសដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រទាំងឡាយក៏បោះឆ្នោតឲ្យឈ្មោះបេក្ខជនណាមួយដែលគាប់ចិត្តខ្លួន ៗ បោះឆ្នោត គឺយល់ព្រមទទួលយកឬមិនយល់ព្រមទទួលយកបេក្ខជនណាមួយធ្វើជាអ្នកតំណាងខ្លួន ៗ អធិបតេយ្យនៃបណ្ដាជនទាំងឡាយនឹងអាចប្រព្រឹត្តិទៅបានដោយសារការជ្រើសតាំងអ្នកតំណាងនេះ ដ្បិតអ្នកតំណាងនេះហើយ ដែលជាអ្នកសម្រេចការផ្សេង ៗ និងចាត់ចែងកិច្ចការនានា ក្នុងការគ្រប់គ្រងប្រទេសព្រមទាំងជាអ្នកតែងច្បាប់ក្នុងនាមបណ្ដាជនផង ។

ការបោះឆ្នោតជាការមួយសំខាន់ណាស់ចំពោះប្រទេស ពីព្រោះភោគវាសនារបស់ប្រទេសថិតនៅក្នុងកណ្ដាប់ដៃនៃអ្នកតំណាងរាស្ត្រ ។ រដ្ឋធម្ម-

នុញ្ញប្រទេសកម្ពុជាបើកឲ្យបុរសស្ត្រីទាំងអស់មានសិទ្ធិជ្រើសតាំងអ្នកតំណាង ដូច្នេះបណ្ដាជនទាំងឡាយត្រូវប្រើសិទ្ធិនេះឲ្យពេញលេញ ។ មិនបញ្ចេញមតិជ្រើសតាំងគឺលះបង់ចោលអំណាចដែលខ្លួនមាន ដើម្បីជួយជ្រោមជ្រែងរបៀបចាត់ចែងការគ្រប់គ្រងប្រទេស ។ ជ្រើសតាំងដោយទុច្ចរិតគឺព្រានប្រទេសទាំងមូលទៅក្នុងភយន្តរាយផ្សេងៗ ។

ហេតុនេះពលរដ្ឋម្នាក់ៗមានករណីយកិច្ចនឹងជ្រើសតាំងអ្នកតំណាងខ្លួនឲ្យត្រឹមត្រូវគឺថា៖ ជ្រើសតាំងដោយឥតទាក់ទិននឹងលាភផលប្រយោជន៍ដទៃ ដោយឯកច្ឆន្ទចិត្តឥតមានអ្នកឯណាបង្ខិតបង្ខំ គឺជ្រើសតាំងតាមសម្បជញ្ញៈខ្លួន ។

ត្រូវបោះឆ្នោតឲ្យបេក្ខជនណាដែលយើងជឿជាក់ថាមានសម្បទានឹងធ្វើការឲ្យប្រទេសបាន ។

---

## មេសូត្រត់មាត់

(សម្រាប់គ្រប់ថ្នាក់)

### ១- បេះមកពីរៀនមានមកពីរក

វិជ្ជាទាំងឡាយ ក្រក្រែគម្សាយ ក្នុងនាលោកិយ

ទោះពិបាកតឹង    យ៉ាងណានោះក្តី    បើខំឃ្មាតខ្មី
ព្យាយាមសិក្សា ៗ    សង្វាតសូត្ររៀន    មិនខ្ជិលអៀនប្រៀន
គ្រប់ពេលវេលា    គន់តែនឹងចេះ    បំណះវិជ្ជា
ដំរិះនានា    ចេះមកពីរៀន ៗ
ទ្រព្យផងមានមក    ខំប្រឹងលៃលក    រិះរកធនធាន
ព្យាយាមសន្សំ    រកស៊ីទើបមាន    សម្បូរធនធាន
សម្បត្តិទាំងឡាយ ៗ    រកបានមកពិត    ឲ្យមានគំនិត
ខំគិតតែចាយ    រក្រាទុកដាក់    កុំឲ្យអន្តរាយ
ទ្រព្យធនទាំងឡាយ    មានមកពីរក ៗ    កុមារទាំងឡាយ
ខំប្រឹងខ្វល់ខ្វាយ    ត្រិះរិះរៀនយក    ជំជើង់ខ្ពនអ្នក
មិនធ្លាក់ជ្រុលជ្រក    ពាក្យពិតមានមក    ពីបុរាណនាយ ៗ

ពន្យល់ពាក្យ.- អម្បាយ = យូរអង្វែង ៗ អៀនប្រៀន= មុខមូរ
ក្រអឹមក្រអៀម ៗ ធនធាន= ទ្រព្យ ៗ
អន្តរាយ= ខូច វិនាស ៗ
ត្រិះរិះ= គិតពិចារណា ៗ

## ២.- អំពីពេល-វេលា

ពេលព្រឹកពេលយប់ ពេលល្ងាចព្រលប់ អធ្រាត្រពេលថ្ងៃ
ថ្ងៃនេះថ្ងៃមុន ថ្ងៃម្សិលម្សិលម៉្ងៃ មានពាក្យច្រើនក្រៃ
ហៅពេលវេលា ៗ ពេលចែកជាឆ្នាំ រៀនកប់ចំណាំ
ដប់ពីរមាសា ប្ដូកប់ជាថ្ងៃ បីរយទិវា
ហុកសិបប្រាំជា មួយឆ្នាំប្រាកដ ៗ ប្រក្រតិទិន
កត់សំគាល់គឹន ខែថ្ងៃកំណត់ ដូចពេលបុណ្យភ្ជុំ
អុំទូកកាត់ព្រ័ត្រ ធ្វើតាមកំណត់ ដល់ពេលវេលា ៗ
ក្នុងមួយឆ្នាំត្រូវ ចែកជារដូវ នោះមានបីគ្រា
រដូវខែប្រាំង រដូវរងា រដូវវស្សា
គឺខែវសន្ត ៗ មួយឆ្នាំពិនិត្យ ហាសិបពីរពិត
អាទិត្យគ្រប់គ្រាន់ មួយត្រីមាសមាន បីខែជាក់ស្បាន់
ឆមាសក្នុងកាន់ ប្រាំមួយមាសា ៗ ពេលចែកសព្វគ្រប់
មួយថ្ងៃមួយយប់ តាមម៉ោងនាលិកា ម្ភៃបួនម៉ោង
គេចែកពេលជា ថ្ងៃយប់ដូចគ្នា មានម៉ោងដប់ពីរ

មួយសតវត្សរ៍ មួយរយឆ្នាំគត់ តាមបទវិធី
បែកពេលវេលា នេះជាគម្ពីរ និយាយអំពី
ពេលមានច្រើនក្រៃ ។

ពន្យល់ពាក្យ.— មាសា= ខែ ។ ទិវា= ថ្ងៃ ។
ត្រ័ត្រ= ព្រះឬស្សីត្រគួញធ្វើហើយ ឬកគោជាដើម ។
វសន្ត= មាន ២ ខែរាប់ពីថ្ងៃ ១ កើតខែផល្គុនដល់ថ្ងៃ ១៥ កើតខែពិសាខ, រដូវឈើជ្រុះណាស់ស្លឹក ។
ត្រីមាស= បីខែ ។ ឆមាស= ប្រាំមួយខែ ។
សតវត្សរ៍= ឆ្នាំ១រយ, មួយខួបរយឆ្នាំ ។
គម្ពីរ=ក្បួន, ច្បាប់ ។

---

## ៣.— ខ្យល់ជំនោរ

ខែប្រាំផាំផរ៉ះ ខ្យល់បក់ពីទិស ទីខាងនិរតី
ហៅខ្យល់ជំនោរ វាយោជូនថ្មី ត្រជាក់សរី-

រះកាយសព្វសត្វ ។ ដំនោរខ្យល់ជូន ពពកពពួន

ជូនជាសន្ធាក់ អណ្តែតរំផាយ ព្រះពាយរសាត់

ខ្យល់បក់ផាយផាត់ ខ្ចាយខ្ចាត់ពាសពេញ ។ មេឃាដ៏ងឹត

ពពកបាំងជិត ខ្មៅជាំជុំវិញ បណ្តាលជាភ្លៀង

ធ្លាក់មកពាសពេញ ហើយស្រាងទៅវិញ ដូចដើមធម្មតា ។

ដំណាំដាំដុះ មានកំណាំងស្រុះ ជ្រុះជន្លូរគ្រា

ព្រោះខ្យល់ដំនោរ បក់មកគាលណា ចំរើនផលា-

នុផលទាំងឡាយ ។

ពន្យល់ពាក្យ.- ខ្យល់ដំនោរ= ខ្យល់បក់ជូនមកពីទិសនិរតី ។ វាយោ= ខ្យល់ ។ សរីរ= (មើលថា:សរីរៈ) អត្តភាព, រូប, រាងកាយ ។ ព្រះពាយ= ខ្យល់ ។ មេឃា= មេឃ ។ គ្រា= ជន្លូរ ស៊ីស៊ុកដំណាំរាំង-តួង ។ ផលានុផល= ផ្លែឈើតូចធំ ។

## ៤- ពេលឈប់សម្រាករៀន

កូនសិស្សរៀនសូត្រវិទ្យាសាស្ត្រ    ច្រើនណាស់នាំឲ្យវុឌ្ឍិការណ៍
ពេលឈប់សម្រាករៀនសិក្សា    រាជការកំណត់ពីរខែពិត ។
ដើម្បីលំហែលំហើយកាយ    សប្បាយរីករាយដូរគំនិត
វិស្សមមាសមានកំរិត    គិតពីដប់បួនកក្កដា ។
រៀងរៀបដរាបអង្វែងក្រៃ    ដល់ថ្ងៃដប់បួនខែកញ្ញា
សម្រាកវិហារយាត្រា    ទៅកាន់គ្រឹះហាខ្លួនទីទៃ ។
ដើម្បីសក្ការសម្មាន    សន្តានព្រៀងលានឯនាយនៃ
ជួយធ្វើការងារកិច្ចប្រពៃ    ភ្ជួរដីដកស្ទូងតាមធម្មតា ។
ខ្វះក៏មិនទៅ: នៅបំពេញ    ខំរៀនទន្ទេញតាមប្រាថ្នា
ផុតពេលទំនេរវស្សមាសា    ចូលកាន់សាលាធម្មតាវិញ ។
ជួបជុំកូនសិស្សទាំងប៉ុន្មាន    មកពីគ្រឹះស្ថានមូលពាសពេញ
ចាប់រៀនសិក្សាសូត្រទន្ទេញ    បំពេញវិទ្យាជានិរន្តរ៍ ។

ពន្យល់ពាក្យ.- វិទ្យាសាស្ត្រ= គម្ពីរប្រាប់វិជ្ជាផ្សេងៗ ។ វុឌ្ឍិការណ៍= ហេតុដែល នាំឲ្យមានសេចក្តីចំរើន ។ វិស្សមមាស=( មើល

ថាៈ វិស្សៈ ម៉ៈ មាសៈ ) សម្រាករៀន ។ វិហារយាត្រា= (វិហារៈយា-ត្រា ) ការដើរលេងសប្បាយ ។ សក្ការសម្មាន= ( សក្ការៈសៈម៉ាន ) សេចក្ដីរាប់អាន, សេចក្ដីគួរសម ។ ទ្វេមាសា= ( ទ្វេ =ពីរ ) ពីរខែ ។ និរន្តរ៍= ដែលឥតមានចន្លោះ, រកពេលគ្មាន ។

## ៥ – ព្រះរាជពិធីបុណ្យពុះផែ

ព្រះរាជពិធីទីនាវា នាមាហៅបុណ្យទ្រង់ពុះផែ
ទំនៀមគ្រប់ក្សត្រស្ដេចយើងខ្មែរ ក្រសែបុរាណមួយឆ្នាំម្ដង ។
ត្រូវរៀបពលិការទេវតាថ្មី ប្រុសស្រីស្រុកស្រែចំការផង
នោះនៅជិតឆ្ងាយទៅគឹកកង បំណាំងមើលស្ដេច, ទូកប្រណាំង ។
បណ្ដែតកន្ទោងពេលរាត្រី មានស្រីល្បែងល្បំភ្លើងភ្លឺចាំង
គ្រប់ជាតិខ្មែរចិនយួនចាំពាំង ពេញពាសមាត់ច្រាំងចតុមុខ ។

ពន្យល់ពាក្យ.– ព្រះរាជពិធី= របៀបកិច្ចការធ្វើបុណ្យឬការមង្គលនិមួយក្នុងព្រះរាជដំណាក់ឬក្នុងព្រះរាជវាំង ។ នាវា= ទូកកប៉ាល់ជាដើម ។ ក្រសែ= ដំនួរវង្សត្រកូល ។ ពលិការ គឺកិរិយាធ្វើនូវពលិ ។

រោងពុម្ពខ្មែរ